ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៣៥០.....សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមសំណើរបស់និយ័តករគណនេយ្យនិងសវនកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១._**

ត្រូវបានដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ចំនួន ២ គឺៈ

១. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង

២. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន "ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ"។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ១ នៃប្រកាសនេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២._**

និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាចចេញគោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ និងត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសស្តង់ដាគណនេយ្យដល់គណនេយ្យករសាធារណៈ តាមការចាំបាច់។

និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវធ្វើបច្ចុប្បន្នភាពស្តង់ដាគណនេយ្យសាធារណៈកម្ពុជា និងចេញផ្សាយសម្រាប់ការអនុវត្ត ស្របតាមបរិបទរបស់អន្តរជាតិ ក្នុងករណីចាំបាច់។

**ប្រការ៣._**

អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងនាមជាគណនេយ្យករសាធារណៈ ត្រូវកត់ត្រា និងប្រមូលផ្តុំនូវប្រតិបត្តិការចំណូល និងដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ព្រមទាំងលាតត្រដាងព័ត៌មានអំពីចំណូល និងគណនីត្រូវទទួលពាក់ព័ន្ធ ឱ្យស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ចាប់ពីថ្ងៃចេញប្រកាសនេះ អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធគណនេយ្យសាធារណៈ ឱ្យបានរួចរាល់ និងត្រូវចាប់ផ្តើមអនុវត្តជាបណ្តើរៗ សម្រាប់ការអនុវត្តគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល ២០២៥-២០២៧ ជាផ្លូវការ។

**ប្រការ៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការក្រសួង អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយក

ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២៣ ស្តីពី ចំណូលពីប្រតិបត្តិការមិនដោះដូរ (ពន្ធ និង ការផ្ទេរ)

## ការទទួលស្គាល់

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា (CPSAS) លេខ ២៣ ត្រូវបានរៀបចំដោយផ្អែកលើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSAS) 23, ចំណូលពីប្រតិបត្តិការមិនដោះដូរ (ពន្ធ និង ការផ្ទេរ), ចេញពីសៀវភៅសេចក្តីប្រកាសគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ របស់ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ(IPSASB) ដែលបានចេញផ្សាយដោយសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC) នៅក្នុងខែកក្កដា ឆ្នាំ២០២០ ហើយត្រូវបានប្រើប្រាស់ដោយមានការអនុញ្ញាតពីសហព័ន្ធគណនេយ្យករអន្តរជាតិ។

សៀវភៅសេចក្តីប្រកាសគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ©2020 ដោយសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC)។ សូមរក្សាសិទ្ធិគ្រប់យ៉ាង។

ចេញផ្សាយដោយ÷

និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ

លេខទូរស័ព្ទ÷ +(855) 23 882 111

អ៊ីម៉ែល÷ info@acar.gov.kh

គេហទំព័រ÷ www.acar.gov.kh

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២៣ ស្តីពី ចំណូលពីប្រតិបត្តិការមិនដោះដូរ (ពន្ធ និង ការផ្ទេរ)

## មាតិកា


កថាខណ្ឌ

គោលបំណង.......... ១
វិសាលភាព.......... ២-៦
និយមន័យ.......... ៧-២៨
ប្រតិបត្តិការមិនដោះដូរ.......... ៨-១១
ចំណូល.......... ១២-១៣
លក្ខន្តិកៈ.......... ១៤-១៦
លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ.......... ១៧-១៨
ការរឹតត្បិតលើទ្រព្យសកម្មដែលបានផ្ទេរ.......... ១៩
ភាពជាក់ស្តែងលើទម្រង់ច្បាប់.......... ២០-២៥
ពន្ធ.......... ២៦-២៨
ការវិភាគលំហូរចូលដំបូងនៃធនធានពីប្រតិបត្តិការមិនដោះដូរ.......... ២៩
ការទទួលស្គាល់ទ្រព្យសកម្ម.......... ៣០-៤៣
ការគ្រប់គ្រងទ្រព្យសកម្ម.......... ៣២-៣៣
ព្រឹត្តិការណ៍នាពេលអតីត.......... ៣៤
លំហូរចូលនៃធនធានដែលអាចនឹងកើតមានឡើង.......... ៣៥
ទ្រព្យសកម្មយថាហេតុ.......... ៣៦
វិភាគទានពីម្ចាស់.......... ៣៧-៣៨
សមាសធាតុដោះដូរ និងសមាសធាតុមិនដោះដូរនៃប្រតិបត្តិការមួយ.......... ៣៩-៤១
ការវាស់វែងទ្រព្យសកម្មនាការទទួលស្គាល់លើកដំបូង.......... ៤២-៤៣
ការទទួលស្គាល់ចំណូលពីប្រតិបត្តិការមិនដោះដូរ.......... ៤៤-៤៧
ការវាស់វែងចំណូលពីប្រតិបត្តិការមិនដោះដូរ.......... ៤៨-៤៩
កាតព្វកិច្ចបច្ចុប្បន្នដែលបានទទួលស្គាល់ជាបំណុល.......... ៥០-៥៨
កាតព្វកិច្ចបច្ចុប្បន្ន.......... ៥១-៥៤
លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ.......... ៥៥-៥៦
ការវាស់វែងបំណុលនាការទទួលស្គាល់លើកដំបូង.......... ៥៧-៥៨

ពន្ធ.......... ៥៩-៧៥
ព្រឹត្តិការណ៍ជាប់ពន្ធ.......... ៦៥
ចំណូលសារពើពន្ធដែលបានទទួលមុន .......... ៦៦
ការវាស់វែងទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធ.......... ៦៧-៧០
ចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធ និងចំណាយសារពើពន្ធ.......... ៧១-៧៥
ការផ្ទេរ .......... ៧៦-១០៥ខ
ការវាស់វែងទ្រព្យសកម្មដែលបានផ្ទេរ.......... ៨៣
ការអនុគ្រោះបំណុល និងការសន្មតបំណុល.......... ៨៤-៨៧
ការផាកពិន័យ .......... ៨៨-៨៩
អច្ច័យទាន.......... ៩០-៩២
កាដូ និងការបរិច្ចាគ រួមបញ្ចូលទាំងទំនិញដែលបានពីការបរិច្ចាគ.......... ៩៣-៩៧
សេវាដែលបានពីការបរិច្ចាគ.......... ៩៨-១០៣
វត្ថុបញ្ចាំ.......... ១០៤
ចំណូលពីការផ្ទេរដែលបានទទួលមុន .......... ១០៥
កម្ចីសម្បទាន.......... ១០៥ក-១០៥ខ
ការលាតត្រដាង.......... ១០៦-១១៥

# ចំណូលពីប្រតិបត្តិការមិនដោះដូរ
# (ពន្ធ និង ការផ្ទេរ)

## គោលបំណង

១. គោលបំណងនៃស្តង់ដានេះ គឺដើម្បីកំណត់អំពីលក្ខខណ្ឌចាំបាច់សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុអំពីចំណូលដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរ ជាជាងប្រតិបត្តិការមិនដោះដូរដែលបង្កើតឱ្យមានការរួមបញ្ចូលវិស័យសាធារណៈ។ ស្តង់ដានេះអនុវត្តចំពោះប្រតិបត្តិការដែលចាំបាច់ត្រូវពិចារណាក្នុងការទទួលស្គាល់និងការវាស់វែងចំណូលពីប្រតិបត្តិការមិនដោះដូរ រួមបញ្ចូលទាំងការកំណត់អត្តសញ្ញាណនៃវិភាគទានពីម្ចាស់។

## វិសាលភាព

**២. ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុស្របតាមគណនេយ្យមូលដ្ឋានបង្គរ ត្រូវអនុវត្តស្តង់ដានេះសម្រាប់ការទទួលស្គាល់ចំណូលពីប្រតិបត្តិការមិនដោះដូរ។ ស្តង់ដានេះមិនអនុវត្តចំពោះ÷**

**(ក) ការរួមបញ្ចូលវិស័យសាធារណៈដែលជាប្រតិបត្តិការមិនដោះដូរ និង**

**(ខ) វិភាគទានទៅកាន់ផែនការអត្ថប្រយោជន៍សង្គមដែលត្រូវបានទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ ២៦-៣១ នៃស្តង់ដា CPSAS 42, អត្ថប្រយោជន៍សង្គម (វិធីសាស្ត្រធានារ៉ាប់រង)។**

៣. [លុបចេញ]

៤. [លុបចេញ]

៥. ស្តង់ដានេះបង្ហាញពីចំណូលដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរ។ ចំណូលដែលកើតឡើងពីប្រតិបត្តិការដោះដូរ ត្រូវបានបង្ហាញនៅក្នុងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាស្តីពី ចំណូលពីប្រតិបត្តិការដោះដូរ។ ខណៈពេលដែលចំណូលដែលទទួលបានដោយស្ថាប័នសាធារណៈកើតឡើងពីប្រតិបត្តិការដោះដូរ និងប្រតិបត្តិការមិនដោះដូរ, ចំណូលភាគច្រើនរបស់រាជរដ្ឋាភិបាលនិងស្ថាប័នសាធារណៈផ្សេងទៀត ជាធម្មតាកើតឡើងពីប្រតិបត្តិការមិនដោះដូរ ដូចជា÷

(ក) ពន្ធ និង

(ខ) ការផ្ទេរ (អាចជាសាច់ប្រាក់ ឬ មិនមែនសាច់ប្រាក់) រួមបញ្ចូលទាំងអំណោយ, ការអនុគ្រោះបំណុល, ការផាកពិន័យ, អច្ច័យទាន, កាដូ, ការបរិច្ចាគ, ទំនិញនិងសេវាដែលបានពីការបរិច្ចាគ និងចំនួនកម្ចីសម្បទានដែលមានការប្រាក់ទាបជាងទីផ្សារដែលស្ថាប័នបានទទួល។

៦. រាជរដ្ឋាភិបាលអាចរៀបចំវិស័យសាធារណៈឡើងវិញ ដោយបញ្ចូលស្ថាប័នសាធារណៈមួយចំនួនចូលគ្នា និង បំបែកស្ថាប័នសាធារណៈផ្សេងទៀតជាពីរស្ថាប័ន ឬ ច្រើនស្ថាប័នដាច់ដោយឡែកពីគ្នា។ ការរួមបញ្ចូលវិស័យសាធារណៈកើតឡើងនៅពេលដែលប្រតិបត្តិការពីរ ឬ ច្រើន ត្រូវបានច្របាច់បញ្ចូលគ្នាដើម្បីបង្កើតបានជាស្ថាប័នរាយការណ៍មួយ។ ការរៀបចំរចនាសម្ព័ន្ធឡើងវិញទាំងនេះ ជាធម្មតាមិនជាប់ពាក់ព័ន្ធនឹងស្ថាប័នមួយធ្វើការបញ្ជាទិញកិច្ចប្រតិបត្តិការ ឬ ស្ថាប័នដទៃនោះទេ ប៉ុន្តែអាចបង្កើតឱ្យមានស្ថាប័នថ្មី ឬ ស្ថាប័នដែលមានស្រាប់មួយធ្វើការទិញរាល់ទ្រព្យសកម្មនិងបំណុលនៃកិច្ចប្រតិបត្តិការ ឬ ស្ថាប័នដទៃ។ ការរួមបញ្ចូលវិស័យសាធារណៈ ត្រូវទទួលស្គាល់ ដោយអនុលោមតាមស្តង់ដា CPSAS 40, ការរួមបញ្ចូលវិស័យសាធារណៈ។

## និយមន័យ

៧. **វាក្យស័ព្ទដែលបានប្រើប្រាស់នៅក្នុងស្តង់ដានេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷**

លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ គឺជាលក្ខន្តិកៈដែលកំណត់ថា អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដែលមាននៅក្នុងទ្រព្យសកម្ម ត្រូវបានតម្រូវឱ្យប្រើប្រាស់ដោយអ្នកទទួលផល ដូចបានកំណត់ ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ត្រូវប្រគល់ត្រលប់ទៅឱ្យអ្នកផ្ទេរវិញ។

ការគ្រប់គ្រងទ្រព្យសកម្ម កើតឡើងនៅពេលស្ថាប័នអាចប្រើប្រាស់ ឬ ទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្ម ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន ហើយអាចដកចេញ ឬ គ្រប់គ្រងសិទ្ធិរបស់អ្នកដទៃក្នុងការទទួលបានអត្ថប្រយោជន៍នោះ។

ចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធ គឺជាចំនួនទឹកប្រាក់ដែលអត្ថគាហកៈអាចទទួលបាន ដោយមិនគិតថាតើអត្ថគាហកៈទាំងនោះ បង់ពន្ធ ឬ មិនបង់ពន្ធឡើយ។

ការផាកពិន័យ គឺជាអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលបានទទួល ឬ ត្រូវទទួលដោយស្ថាប័នសាធារណៈ ដូចបានកំណត់ដោយតុលាការ ឬ ស្ថាប័នអនុវត្តច្បាប់ផ្សេងទៀត ដែលជាលទ្ធផលនៃការបំពានច្បាប់ ឬ បទប្បញ្ញត្តិផ្សេងៗ។

ការរឹតត្បិតលើទ្រព្យសកម្មដែលបានផ្ទេរ គឺជាលក្ខន្តិកៈដែលកម្រិត ឬ ដឹកនាំគោលបំណងដែលទ្រព្យសកម្មដែលបានផ្ទេរ អាចត្រូវបានប្រើប្រាស់ ប៉ុន្តែមិនកំណត់ថា អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ត្រូវបានតម្រូវឱ្យប្រគល់ត្រលប់ទៅឱ្យអ្នកផ្ទេរទេ ប្រសិនបើមិនត្រូវបានប្រើប្រាស់ដូចបានកំណត់។

លក្ខន្តិកៈលើទ្រព្យសកម្មដែលបានផ្ទេរ គឺជាលក្ខខណ្ឌនៅក្នុងច្បាប់ ឬ បទប្បញ្ញត្តិ ឬ កិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្ត ដែលត្រូវបានកំណត់លើការប្រើប្រាស់ទ្រព្យសកម្មដែលបានផ្ទេរដោយស្ថាប័នក្រៅពីស្ថាប័នរាយការណ៍។

<u>ចំណាយសារពើពន្ធ</u> គឺជាការអនុគ្រោះពន្ធ តាមរយៈច្បាប់និងបទប្បញ្ញត្តិដែលផ្តល់ឱ្យអ្នកជាប់ពន្ធជាក់លាក់នូវសម្បទាន ដែលសម្បទាននោះមិនត្រូវបានផ្តល់ឱ្យអ្នកជាប់ពន្ធផ្សេងទៀត។

<u>ព្រឹត្តិការណ៍ជាប់ពន្ធ</u> គឺជាព្រឹត្តិការណ៍ដែលរាជរដ្ឋាភិបាល, ស្ថាប័ននីតិប្បញ្ញត្តិ ឬ អាជ្ញាធរផ្សេងទៀតបានកំណត់ថានឹងត្រូវជាប់ពន្ធ។

<u>ពន្ធ</u> គឺជាអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលបានបង់ជាចាំបាច់ ឬ ត្រូវបង់ទៅស្ថាប័នសាធារណៈ អនុលោមតាមច្បាប់ និង/ឬ បទប្បញ្ញត្តិស្តីពីពន្ធជាធរមាន ហើយត្រូវបានបង្កើតឡើងដើម្បីផ្តល់ចំណូលដល់រាជរដ្ឋាភិបាល។ ពន្ធមិនរាប់បញ្ចូលនូវការផាកពិន័យ ឬ ទោសផ្សេងទៀតដែលបានកំណត់សម្រាប់ការបំពានច្បាប់នោះទេ។

<u>ការផ្ទេរ</u> គឺជាលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ពីប្រតិបត្តិការមិនដោះដូរ ជាជាងសារពើពន្ធ។

វាក្យស័ព្ទដែលបានកំណត់នៅក្នុងស្តង់ដា CPSAS ផ្សេងទៀត ត្រូវបានប្រើនៅក្នុងស្តង់ដានេះដោយមានអត្ថន័យដូចគ្នានឹងស្តង់ដាទាំងនោះដែរ ហើយត្រូវបានកំណត់ឡើងវិញនៅក្នុង *សទ្ទានុក្រមនៃវាក្យស័ព្ទដែលបានកំណត់និយមន័យ* ដែលត្រូវបានបោះពុម្ពផ្សាយដាច់ដោយឡែក។

### ប្រតិបត្តិការមិនដោះដូរ

៨. នៅក្នុងប្រតិបត្តិការមួយចំនួន វាមានភាពច្បាស់លាស់ដែលមានការដោះដូរក្នុងតម្លៃស្មើប្រហាក់ប្រហែល។ ប្រតិបត្តិការទាំងនោះ គឺជាប្រតិបត្តិការដោះដូរ ហើយត្រូវបានបង្ហាញនៅក្នុងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាផ្សេងទៀត។

៩. នៅក្នុងប្រតិបត្តិការផ្សេងទៀត ស្ថាប័ននឹងទទួលបានធនធាន ហើយមិនផ្តល់ ឬ ផ្តល់តម្លៃតបស្នងពិតដោយផ្ទាល់ត្រលប់ទៅវិញទេ។ ប្រតិបត្តិការទាំងនោះ គឺជាប្រតិបត្តិការមិនដោះដូរ ហើយត្រូវបានបង្ហាញនៅក្នុងស្តង់ដានេះ។ ឧទាហរណ៍ អ្នកជាប់ពន្ធ ត្រូវបង់ពន្ធ ពីព្រោះច្បាប់ពន្ធបានកំណត់ឱ្យធ្វើការបង់ពន្ធ។ ការផ្តល់សេវាសាធារណៈជាច្រើនរបស់រាជរដ្ឋាភិបាលដល់អ្នកជាប់ពន្ធ មិនត្រូវបានចាត់ទុកជាការតបស្នងចំពោះការបង់ពន្ធនោះទេ។

១០. មានប្រតិបត្តិការមិនដោះដូរមួយក្រុមផ្សេងទៀតដែលស្ថាប័នអាចផ្តល់តម្លៃតបស្នងដោយផ្ទាល់ជាថ្នូរក្នុងការទទួលបានធនធាន ប៉ុន្តែតម្លៃតបស្នងនោះ មិនស្មើនឹងតម្លៃសមស្របនៃធនធានដែលបានទទួលទេ។ នៅក្នុងករណីទាំងនេះ ស្ថាប័នកំណត់ថាតើមានការរួមបញ្ចូលគ្នារវាងប្រតិបត្តិការដោះដូរ និងប្រតិបត្តិការមិនដោះដូរដែរឬទេ ដែលធាតុនីមួយៗនៃប្រតិបត្តិការទាំងនេះត្រូវបានទទួលស្គាល់ដាច់ដោយឡែកពីគ្នា។ ឧទាហរណ៍ ស្ថាប័នមួយទទួលបានមូលនិធិ ៦ លានអឺរ៉ូ ពីទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគី។ កិច្ចព្រមព្រៀងចែងថា ស្ថាប័នត្រូវទូទាត់សង ៥ លានអឺរ៉ូ ក្នុងរយៈពេល ១០ ឆ្នាំ ក្នុងអត្រាការប្រាក់ ៥% នៅពេលដែល

អត្រាទីផ្សារសម្រាប់កម្ចីប្រហាក់ប្រហែលគឺ ១១%។ ស្ថាប័នទទួលបាន ១ លានអឺរ៉ូ ជាអំណោយ (៦ លានអឺរ៉ូ ដក ៥ លានអឺរ៉ូដែលបានទូទាត់សង) ហើយកត់ត្រាជាកម្ចីសម្បទានចំនួន ៥ លានអឺរ៉ូ ដែលចំណេញបានអត្រាការប្រាក់ ៦% ទាបជាងអត្រាការប្រាក់ទីផ្សារ សម្រាប់កម្ចីប្រហាក់ប្រហែល។ អំណោយចំនួន ១ លានអឺរ៉ូដែលបានទទួល ព្រមទាំងចំនួនទឹកប្រាក់មួយផ្នែកនៃការទូទាត់សងការប្រាក់ក្រៅទីផ្សារនៃកិច្ចព្រមព្រៀង គឺជាប្រតិបត្តិការមិនដោះដូរ។ ការទូទាត់សងការប្រាក់ និងប្រាក់ដើមនៃកិច្ចសន្យាពេញមួយអាយុកាលនៃកម្ចី គឺជាប្រតិបត្តិការដោះដូរ។

១១. លើសពីនេះ ក៏មានប្រតិបត្តិការមួយចំនួនដែលមិនបានបង្ហាញភ្លាមៗឱ្យច្បាស់ថាជាប្រតិបត្តិការដោះដូរ ឬ ប្រតិបត្តិការមិនដោះដូរផងដែរ។ ក្នុងករណីបែបនេះ ការពិនិត្យលើភាពជាក់ស្តែងនៃប្រតិបត្តិការ នឹងកំណត់ថាតើប្រតិបត្តិការទាំងនោះជាប្រតិបត្តិការដោះដូរ ឬ ប្រតិបត្តិការមិនដោះដូរ។ ឧទាហរណ៍ ការលក់ទំនិញ ជាទូទៅត្រូវបានចាត់ថ្នាក់ជាប្រតិបត្តិការដោះដូរ។ ប៉ុន្តែ ប្រសិនបើប្រតិបត្តិការត្រូវបានធ្វើឡើងក្នុងតម្លៃឧបត្ថម្ភធន ពោលគឺតម្លៃដែលមានតម្លៃមិនស្មើប្រហាក់ប្រហែលនឹងតម្លៃសមស្របនៃទំនិញដែលបានលក់, ប្រតិបត្តិការនោះស្ថិតក្នុងនិយមន័យនៃប្រតិបត្តិការមិនដោះដូរ។ ក្នុងការកំណត់ថាតើភាពជាក់ស្តែងនៃប្រតិបត្តិការមួយ គឺជាភាពជាក់ស្តែងនៃប្រតិបត្តិការមិនដោះដូរ ឬ ប្រតិបត្តិការដោះដូរ, ការវិនិច្ឆ័យបែបវិជ្ជាជីវៈ នឹងត្រូវធ្វើឡើង។ លើសពីនេះ ស្ថាប័នអាចទទួលបានអប្បហារពាណិជ្ជកម្ម, អប្បហារលើបរិមាណទំនិញ ឬ ការថយចុះតម្លៃកំណត់ផ្សេងទៀតនៃទ្រព្យសកម្មសម្រាប់ហេតុផលផ្សេងៗគ្នា។ ការថយចុះតម្លៃទាំងនេះមិនមែនប្រាកដថា ប្រតិបត្តិការនោះគឺជាប្រតិបត្តិការមិនដោះដូរនោះទេ។

**ចំណូល**

១២. ចំណូល រួមមានលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលទទួលបាន និងត្រូវទទួល ដោយស្ថាប័នរាយការណ៍ ដែលតំណាងឱ្យការកើនឡើងនៃទ្រព្យសកម្ម ឬ មូលធនសុទ្ធ ជាជាងការកើនឡើងនៃវិភាគទានពីម្ចាស់។ ចំនួនទឹកប្រាក់ដែលប្រមូលបានក្នុងនាមជាភ្នាក់ងាររាជរដ្ឋាភិបាល ឬ ស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ឬ ភាគីទីបីដទៃទៀត នឹងមិនធ្វើឱ្យមានការកើនឡើងនៃទ្រព្យសកម្មសុទ្ធ ឬ ចំណូលរបស់ភ្នាក់ងារទេ។ ករណីនេះពីព្រោះស្ថាប័នជាភ្នាក់ងារ មិនអាចគ្រប់គ្រងលើការប្រើប្រាស់ ឬ ការទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មដែលប្រមូលបាន ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន។

១៣. នៅពេលស្ថាប័នបង្កើតចំណាយមួយចំនួនពាក់ព័ន្ធនឹងចំណូលដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរ, ចំណូលនោះ គឺជាលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ហើយលំហូរចេញណាមួយនៃធនធាន ត្រូវបានទទួលស្គាល់ជាថ្លៃដើមនៃប្រតិបត្តិការ។ ឧទាហរណ៍ ប្រសិនបើស្ថាប័នរាយការណ៍ត្រូវបានតម្រូវឱ្យទូទាត់ចំណាយលើការដឹកជញ្ជូននិងការតំឡើង ពាក់ព័ន្ធនឹងការផ្ទេរធាតុមួយនៃទ្រព្យពីស្ថាប័នដទៃមកកាន់ស្ថាប័នខ្លួន ចំណាយទាំងនោះត្រូវបានទទួលស្គាល់ដាច់ដោយឡែកពីចំណូលដែលកើតឡើងពីការផ្ទេរធាតុនៃទ្រព្យនោះ។ ចំណាយលើការដឹកជញ្ជូននិងការតំឡើង ត្រូវបាន

បញ្ចូលក្នុងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ជាទ្រព្យសកម្ម ដោយអនុលោមតាមស្តង់ដា CPSAS 17, ទ្រព្យ រោងចក្រ និងបរិក្ខារ។

**លក្ខន្តិកៈ**

១៤. ទ្រព្យសកម្ម អាចត្រូវបានផ្ទេរ ជាមួយនឹងការរំពឹងទុក និង/ឬ ការយល់ថា ទ្រព្យសកម្មទាំងនោះនឹងត្រូវបានប្រើប្រាស់ក្នុងមធ្យោបាយជាក់លាក់ ហើយដូចនេះ ស្ថាប័នជាអ្នកទទួលផល នឹងត្រូវធ្វើសកម្មភាព ឬ អនុវត្តក្នុងមធ្យោបាយជាក់លាក់។ នៅពេលច្បាប់ បទប្បញ្ញត្តិ ឬ កិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្ត ជាមួយភាគីខាងក្រៅ ដាក់លក្ខខណ្ឌលើការប្រើប្រាស់ទ្រព្យសកម្មដែលបានផ្ទេរដោយអ្នកទទួលផល លក្ខខណ្ឌទាំងនេះគឺជាលក្ខន្តិកៈដូចបានកំណត់នៅក្នុងស្តង់ដានេះ។ លក្ខណៈពិសេសមួយនៃលក្ខន្តិកៈដូចបានកំណត់នៅក្នុងស្តង់ដានេះ គឺថា ស្ថាប័នមិនអាចកំណត់លក្ខន្តិកៈចំពោះខ្លួនឯងនោះទេ មិនថាដោយផ្ទាល់ ឬ តាមរយៈស្ថាប័នដែលខ្លួនគ្រប់គ្រង។

១៥. លក្ខន្តិកៈពាក់ព័ន្ធនឹងទ្រព្យសកម្មដែលត្រូវបានផ្ទេរ អាចជាលក្ខខណ្ឌ ឬ ការរឹតត្បិត។ ខណៈដែលលក្ខខណ្ឌ និងការរឹតត្បិត អាចតម្រូវឱ្យស្ថាប័នប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដែលមាននៅក្នុងទ្រព្យសកម្ម សម្រាប់គោលបំណងជាក់លាក់ (កាតព្វកិច្ចអនុវត្ត) នៅពេលទទួលស្គាល់លើកដំបូង, មានតែលក្ខខណ្ឌប៉ុណ្ណោះដែលតម្រូវថា អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ត្រូវប្រគល់ទៅឱ្យអ្នកផ្ទេរវិញ ក្នុងករណីដែលលក្ខន្តិកៈត្រូវបានបំពាន (កាតព្វកិច្ចផ្ទេរត្រលប់)។

១៦. លក្ខន្តិកៈអាចអនុវត្តបានតាមរយៈដំណើរការផ្លូវច្បាប់ ឬ រដ្ឋបាល។ ប្រសិនបើលក្ខខណ្ឌនៅក្នុងច្បាប់ ឬ បទប្បញ្ញត្តិ ឬ កិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្តផ្សេងទៀតមិនអាចអនុវត្តបាន, លក្ខខណ្ឌនោះមិនមែនជាលក្ខន្តិកៈដូចបានកំណត់ដោយស្តង់ដានេះទេ។ កាតព្វកិច្ចបែបស្ថាបនា មិនកើតឡើងពីលក្ខន្តិកៈនោះទេ។ ស្តង់ដា CPSAS 19, សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ បានកំណត់អំពីលក្ខខណ្ឌចាំបាច់សម្រាប់ការទទួលស្គាល់ និងការវាស់វែងកាតព្វកិច្ចបែបស្ថាបនា។

**លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ**

១៧. លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ (ចាប់ពីពេលនេះ សំដៅដល់លក្ខខណ្ឌ) តម្រូវថា ស្ថាប័នប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតនៃទ្រព្យសកម្មដូចបានកំណត់ ឬ ប្រគល់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ត្រលប់ទៅឱ្យអ្នកផ្ទេរវិញ ក្នុងករណីដែលលក្ខខណ្ឌត្រូវបានបំពាន។ ដូចនេះ អ្នកទទួលផល បង្កើតកាតព្វកិច្ចបច្ចុប្បន្នមួយដើម្បីផ្ទេរអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតទៅកាន់ភាគីទីបី នៅពេលដែលអ្នកទទួលផល ទទួលបានការគ្រប់គ្រងលើកដំបូងលើទ្រព្យសកម្មដែលជាប់លក្ខខណ្ឌ។ ករណីនេះគឺ ពីព្រោះអ្នកទទួលផលមិនអាចជៀសវាងពីលំហូរចេញនៃធនធាន នៅពេលអ្នកទទួលផលត្រូវបានតម្រូវឱ្យប្រើប្រាស់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដែលមាននៅក្នុងទ្រព្យសកម្មដែលបានផ្ទេរ ក្នុងការផ្តល់

ទំនិញ ឬ សេវាជាក់លាក់ទៅកាន់ភាគីទីបី ឬ ត្រូវប្រគល់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតត្រលប់ទៅឱ្យអ្នកផ្ទេរវិញ។ ដូចនេះ នៅពេលអ្នកទទួលផល ទទួលស្គាល់ជាលើកដំបូងនូវទ្រព្យសកម្មដែលជាប់លក្ខខណ្ឌ អ្នកទទួលផលក៏បង្កើតជាបំណុល។

១៨. ដើម្បីសម្រួលផ្នែករដ្ឋបាល, ទ្រព្យសកម្មដែលបានផ្ទេរ ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតផ្សេងទៀត អាចត្រូវបានប្រគល់ត្រលប់ទៅវិញប្រកបដោយប្រសិទ្ធភាព ដោយធ្វើការកាត់កងចំនួនទឹកប្រាក់ដែលត្រូវប្រគល់ត្រលប់ទៅវិញ ចេញពីទ្រព្យសកម្មផ្សេងទៀតដែលត្រូវប្រគល់ត្រលប់ទៅវិញដែលមានគោលបំណងផ្សេង។ ស្ថាប័នរាយការណ៍ នឹងនៅតែទទួលស្គាល់ចំនួនទឹកប្រាក់ដុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ពោលគឺ ស្ថាប័ននឹងទទួលស្គាល់ចំនួនទឹកប្រាក់ដែលបានកាត់កងនៅក្នុងទ្រព្យសកម្មនិងបំណុលនោះ សម្រាប់ការប្រគល់ត្រលប់ទៅវិញនៃទ្រព្យសកម្មនោះ ក្រោមលក្ខខណ្ឌដែលត្រូវបានបំពាន ហើយនឹងត្រូវឆ្លុះបញ្ចាំងពីការទទួលស្គាល់ទ្រព្យសកម្ម បំណុល និង/ឬ ចំណូលសម្រាប់ការផ្ទេរថ្មី។

## ការរឹតត្បិតលើទ្រព្យសកម្មដែលបានផ្ទេរ

១៩. ការរឹតត្បិតលើទ្រព្យសកម្មដែលបានផ្ទេរ (ចាប់ពីពេលនេះ សំដៅដល់ការរឹតត្បិត) មិនរាប់បញ្ចូលនូវលក្ខខណ្ឌចាំបាច់ដែល ទ្រព្យសកម្មដែលបានផ្ទេរ ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតផ្សេងទៀត ត្រូវប្រគល់ត្រលប់ទៅឱ្យអ្នកផ្ទេរវិញ ប្រសិនបើទ្រព្យសកម្មនោះមិនត្រូវបានប្រើប្រាស់ដូចបានកំណត់នោះទេ។ ដូចនេះ ការទទួលបានការកាន់កាប់លើទ្រព្យសកម្មដែលរងការរឹតត្បិត មិនបានកំណត់កាតព្វកិច្ចបច្ចុប្បន្នចំពោះអ្នកទទួលផល ក្នុងការផ្ទេរអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតទៅកាន់ភាគីទីបី នៅពេលការកាន់កាប់លើទ្រព្យសកម្មត្រូវបានទទួលជាលើកដំបូងនោះទេ។ នៅពេលដែលអ្នកទទួលផលបំពានលើការរឹតត្បិត, អ្នកផ្ទេរ ឬ ភាគីផ្សេងទៀតអាចមានជម្រើសក្នុងការដាក់ពិន័យចំពោះអ្នកទទួលផល ឧទាហរណ៍ តាមរយៈការលើកយកករណីនេះឡើងទៅតុលាការ ឬ សាលាក្តីផ្សេងទៀត ឬ តាមរយៈនីតិវិធីរដ្ឋបាល ដូចជា សេចក្តីណែនាំពីមន្ត្រីរាជរដ្ឋាភិបាល ឬ អាជ្ញាធរផ្សេងទៀត។ វិធានការទាំងនេះអាចនាំឱ្យស្ថាប័នត្រូវបំពេញនូវការរឹតត្បិតនោះ ឬ ប្រឈមមុខនឹងទោសរដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌសម្រាប់ការប្រឆាំងនឹងតុលាការ, សាលាក្តី ឬ អាជ្ញាធរផ្សេងទៀត។ ការពិន័យបែបនេះ មិនត្រូវបានកើតឡើងដោយសារការទិញទ្រព្យសកម្មនោះទេ ប៉ុន្តែគឺជាលទ្ធផលនៃការបំពានលើការរឹតត្បិត។

## ភាពជាក់ស្តែងលើទម្រង់ច្បាប់

២០. ក្នុងការកំណត់ថាតើលក្ខន្តិកៈ គឺជាលក្ខខណ្ឌ ឬ ការរឹតត្បិត, វាពិតជាមានភាពចាំបាច់ក្នុងការពិចារណាលើភាពជាក់ស្តែងនៃលក្ខខណ្ឌរបស់លក្ខន្តិកៈ និងមិនមែនគ្រាន់តែពិចារណាលើទម្រង់នៃលក្ខន្តិកៈនោះទេ។ ឧទាហរណ៍ ការបញ្ជាក់ដែល ទ្រព្យសកម្មដែលបានផ្ទេរ ត្រូវបានតម្រូវឱ្យប្រើប្រាស់ក្នុងការផ្តល់ទំនិញនិង

សេវា ទៅកាន់ភាគីទីបី ឬ ត្រូវប្រគល់ត្រលប់ទៅឱ្យអ្នកផ្ទេរវិញ គឺមិនគ្រប់គ្រាន់នៅឡើយទេ ដើម្បីបង្កើតបានជាបំណុល នៅពេលស្ថាប័នទទួលបានការកាន់កាប់លើទ្រព្យសកម្មនោះ។

២១. ក្នុងការកំណត់ថាតើលក្ខន្តិកៈមួយ គឺជាលក្ខខណ្ឌ ឬ ការរឹតត្បិត, ស្ថាប័នត្រូវពិចារណាថាតើលក្ខខណ្ឌចាំបាច់ក្នុងការប្រគល់ទ្រព្យសកម្ម ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតផ្សេងទៀត អាចចាប់បង្ខំឱ្យអនុវត្ត ហើយអាចត្រូវបានចាប់បង្ខំឱ្យអនុវត្តដោយអ្នកផ្ទេរបានដែរឬទេ។ ប្រសិនបើអ្នកផ្ទេរមិនអាចចាប់បង្ខំការអនុវត្តលក្ខខណ្ឌចាំបាច់ក្នុងការប្រគល់ទ្រព្យសកម្ម ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតទេ លក្ខន្តិកៈនឹងមិនបំពេញតាមនិយមន័យនៃលក្ខខណ្ឌនោះឡើយ ហើយនឹងត្រូវបានចាត់ទុកជាការរឹតត្បិត។ ប្រសិនបើបទពិសោធន៍នាពេលអតីតជាមួយអ្នកផ្ទេរ បង្ហាញថាអ្នកផ្ទេរមិនធ្លាប់ចាប់បង្ខំការអនុវត្តលក្ខខណ្ឌចាំបាច់ក្នុងការប្រគល់ទ្រព្យសកម្មដែលបានផ្ទេរ ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតផ្សេងទៀត នៅពេលដែលមានការបំពានកើតឡើង, ស្ថាប័នដែលជាអ្នកទទួលផល អាចសន្និដ្ឋានបានថា លក្ខន្តិកៈមានទម្រង់ ប៉ុន្តែមិនមានភាពជាក់ស្តែងនៃលក្ខខណ្ឌនោះទេ ដូចនេះ លក្ខន្តិកៈនោះគឺជាការរឹតត្បិត។ ប្រសិនបើស្ថាប័នមិនមានបទពិសោធន៍ជាមួយអ្នកផ្ទេរ ឬ កន្លងមកមិនធ្លាប់បានបំពានលក្ខន្តិកៈដែលអាចជំរុញឱ្យអ្នកផ្ទេរសម្រេចថាតើត្រូវចាប់បង្ខំឱ្យប្រគល់ទ្រព្យ-សកម្ម ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតផ្សេងទៀត និងមិនមានភស្តុតាងដែលផ្ទុយពីនេះទេ អាចសន្មតបានថា អ្នកផ្ទេរអាចចាប់បង្ខំឱ្យអនុវត្តលក្ខន្តិកៈ ហើយដូចនេះ លក្ខន្តិកៈបំពេញតាមនិយមន័យនៃលក្ខខណ្ឌ។

២២. និយមន័យនៃលក្ខខណ្ឌ បានកំណត់នូវកាតព្វកិច្ចអនុវត្តចំពោះស្ថាប័នដែលជាអ្នកទទួលផល ពោលគឺអ្នកទទួលផល ត្រូវបានតម្រូវឱ្យប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដែលមាននៅក្នុងទ្រព្យសកម្មដែលបានផ្ទេរដូចបានកំណត់ ឬ ត្រូវប្រគល់ទ្រព្យសកម្ម ឬ អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតត្រលប់ទៅឱ្យអ្នកផ្ទេរវិញ។ ដើម្បីបំពេញតាមនិយមន័យនៃលក្ខខណ្ឌ, កាតព្វកិច្ចអនុវត្តនឹងក្លាយជាភាពជាក់ស្តែងមួយដែលមិនមែនជាទម្រង់ ហើយត្រូវបានតម្រូវជាលទ្ធផលដែលកើតចេញពីលក្ខខណ្ឌនោះ។ លក្ខខណ្ឌមួយដែលមាននៅក្នុងកិច្ចព្រមព្រៀងនៃការផ្ទេរដែលតម្រូវឱ្យស្ថាប័នអនុវត្តសកម្មភាពមួយដែលខ្លួនមិនមានជម្រើសប៉ុន្តែត្រូវអនុវត្ត អាចឱ្យស្ថាប័នសន្និដ្ឋានថាលក្ខខណ្ឌនេះមានលក្ខណៈ ទាំងមិនមែនជាលក្ខខណ្ឌ ហើយក៏មិនមែនជា ការរឹតត្បិត។ នេះគឺដោយសារតែក្នុងករណីទាំងនេះ លក្ខខណ្ឌនៃការផ្ទេរ មិនបានកំណត់អំពីកាតព្វកិច្ចអនុវត្តចំពោះស្ថាប័នដែលជាអ្នកទទួលផលនោះទេ។

២៣. ដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាបំណុល វាជាការចាំបាច់ដែលលំហូរចេញនៃធនធានអាចនឹងកើតមានឡើង ហើយការអនុវត្តធៀបនឹងលក្ខខណ្ឌ ត្រូវបានតម្រូវ និងអាចវាយតម្លៃបាន។ ដូចនេះ លក្ខខណ្ឌនឹងចាំបាច់ត្រូវកំណត់លើបញ្ហាដូចជា ចរិតលក្ខណៈ ឬ បរិមាណនៃទំនិញនិងសេវាដែលត្រូវផ្តល់ ឬ ចរិតលក្ខណៈនៃទ្រព្យសកម្មដែលត្រូវទិញ តាមភាពសមស្រប ហើយប្រសិនបើមាន

ភាពជាប់ទាក់ទិន គឺ អំឡុងពេលដែលការអនុវត្តនឹងត្រូវកើតមានឡើង។ លើសពីនេះ ការអនុវត្តនឹងចាំបាច់ត្រូវតាមដានដោយអ្នកផ្ទេរ ឬ ជំនួសឱ្យអ្នកផ្ទេរ ជាប្រចាំ។ ករណីនេះកើតឡើង ជាពិសេសនៅពេលដែលលក្ខន្តិកៈបើកផ្លូវសម្រាប់ការប្រគល់ត្រលប់ទៅវិញនូវតម្លៃសមមូលនៃទ្រព្យសកម្ម ប្រសិនបើស្ថាប័នអនុវត្តលក្ខខណ្ឌចាំបាច់នៃលក្ខណៈបានដោយផ្នែក ហើយកាតព្វកិច្ចក្នុងការប្រគល់ត្រលប់ទៅវិញ ត្រូវបានចាប់បង្ខំឱ្យអនុវត្ត ប្រសិនបើការខកខានមិនបានអនុវត្តសំខាន់ៗបានកើតឡើងនាពេលអតីត។

២៤. នៅក្នុងករណីមួយចំនួន ទ្រព្យសកម្មអាចត្រូវបានផ្ទេរទៅតាមលក្ខន្តិកៈដែលបានចែងថា ទ្រព្យសកម្មនោះត្រូវបានតម្រូវឱ្យប្រគល់ត្រលប់ទៅឱ្យអ្នកផ្ទេរវិញ ប្រសិនបើព្រឹត្តិការណ៍នាពេលអនាគតដែលបានកំណត់មិនបានកើតឡើង។ ករណីនេះអាចកើតឡើងនៅពេលដែល ឧទាហរណ៍ រដ្ឋបាលថ្នាក់ជាតិផ្តល់ថវិកាទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយលក្ខន្តិកៈថា ស្ថាប័នត្រូវចូលរួមវិភាគទានដោយស្មើភាព។ ក្នុងករណីបែបនេះ កាតព្វកិច្ចផ្ទេរត្រលប់មិនកើតឡើងទេ រហូតដល់ពេលមួយដែលលក្ខន្តិកៈនឹងត្រូវបានបំពាន ហើយបំណុលមិនត្រូវបានទទួលស្គាល់នោះទេ រហូតដល់លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ត្រូវបានបំពេញ។

២៥. ទោះបីជាយ៉ាងនេះក្តី អ្នកទទួលផលនឹងចាំបាច់ត្រូវពិចារណាថាតើការផ្ទេរទាំងនេះមានចរិតលក្ខណៈជាចំណូលដែលបានទទួលមុន ឬ យ៉ាងណា។ នៅក្នុងស្តង់ដានេះ ចំណូលដែលបានទទួលមុន សំដៅដល់ធនធានដែលបានទទួលមុនពេលព្រឹត្តិការណ៍ជាប់ពន្ធ ឬ មុនពេលកិច្ចសម្រុះសម្រួលក្នុងការផ្ទេរក្លាយជាកាតព្វកិច្ចត្រូវអនុវត្ត។ ចំណូលដែលបានទទួលមុន បង្កើតឱ្យមាននូវទ្រព្យសកម្ម និងកាតព្វកិច្ចបច្ចុប្បន្ន ពីព្រោះកិច្ចសម្រុះសម្រួលនៃការផ្ទេរមិនទាន់ក្លាយជាកាតព្វកិច្ចត្រូវអនុវត្ត។ នៅពេលការផ្ទេរទាំងនេះមានចរិតលក្ខណៈជាប្រតិបត្តិការដោះដូរ ការផ្ទេរទាំងនេះនឹងត្រូវបានបង្ហាញតាមស្តង់ដា CPSAS 9។

## ពន្ធ

២៦. ពន្ធ គឺជាប្រភពចំណូលដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាលនិងស្ថាប័នសាធារណៈដទៃទៀតជាច្រើន។ ពន្ធត្រូវបានកំណត់ក្នុងកថាខណ្ឌ ៧ ជាអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានបង់ ឬ ត្រូវបង់ ទៅឱ្យស្ថាប័នសាធារណៈ អនុលោមតាមច្បាប់ ឬ បទប្បញ្ញត្តិដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រាក់ចំណូលដល់រាជរដ្ឋាភិបាល តាមបទប្បញ្ញត្តិស្តីពីពន្ធ ដោយមិនរាប់បញ្ចូលនូវការផាកពិន័យ ឬ ការផ្តន្ទាទោសពិន័យជាប្រាក់ផ្សេងទៀត ដែលបានកំណត់សម្រាប់ការបំពានច្បាប់ ឬ បទប្បញ្ញត្តិនោះទេ។ ការផ្ទេរដែលមិនមានកាតព្វកិច្ច ទៅកាន់រាជរដ្ឋាភិបាល ឬ ស្ថាប័នសាធារណៈ ដូចជា ការបរិច្ចាគ និងការបង់កម្រៃសេវា មិនមែនជាពន្ធនោះទេ ទោះបីជាការបរិច្ចាគនិងការបង់កម្រៃសេវាទាំងនោះអាចជាលទ្ធផលនៃប្រតិបត្តិការមិនដោះដូរក៏ដោយ។ រាជរដ្ឋាភិបាលកំណត់ពន្ធលើរូបវន្តបុគ្គល និងនីតិបុគ្គលដទៃទៀតដែលស្គាល់ថាជាអ្នកជាប់ពន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយការប្រើប្រាស់អំណាចអធិបតេយ្យ។

២៧. ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធ អាចមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ពីយុត្តាធិការមួយទៅយុត្តាធិការមួយទៀត ប៉ុន្តែមានបុគ្គលិកលក្ខណៈដូចគ្នាច្រើន។ ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធ (ក)-បង្កើតសិទ្ធិរបស់រាជរដ្ឋា-

ភិបាលក្នុងការប្រមូលពន្ធ; (ខ)-កំណត់មូលដ្ឋានក្នុងការគណនាពន្ធ និង(គ)- បង្កើតនីតិវិធីក្នុងការគ្រប់គ្រងពន្ធ ពោលគឺ នីតិវិធីក្នុងការគណនាពន្ធដែលត្រូវទទួល និងធានាថា ការទូទាត់ត្រូវបានទទួល។ ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធ ភាគច្រើនតម្រូវឱ្យអ្នកជាប់ពន្ធប្រកាសពន្ធតាមការិយបរិច្ឆេទ ទៅកាន់ភ្នាក់ងាររាជរដ្ឋាភិបាលដែលគ្រប់គ្រងពន្ធជាក់លាក់។ អ្នកជាប់ពន្ធ ជាទូទៅផ្តល់ព័ត៌មានលម្អិតនិងភស្តុតាងអំពីកម្រិតសកម្មភាពរបស់ខ្លួនដែលត្រូវជាប់ពន្ធ ហើយចំនួនទឹកប្រាក់ពន្ធដែលរាជរដ្ឋាភិបាលត្រូវទទួល ត្រូវបានគណនា។ កិច្ចសម្រុះសម្រួលសម្រាប់ចំណូលពន្ធ មានភាពខុសគ្នាយ៉ាងទូលំទូលាយ ប៉ុន្តែជាទូទៅត្រូវបានរៀបចំឡើងដើម្បីធានាថា រាជរដ្ឋាភិបាលទទួលបានការទូទាត់ជាទៀងទាត់ ដោយពុំចាំបាច់អនុវត្តវិធានការច្បាប់។ បទប្បញ្ញត្តិស្តីពីពន្ធ ជាធម្មតាត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង និងកំណត់ទោសទណ្ឌធ្ងន់ធ្ងរលើរូបវន្តបុគ្គល ឬ នីតិបុគ្គលដទៃទៀតដែលបំពានច្បាប់។

២៨. ចំណូលដែលទទួលបានមុន ដែលជាចំនួនទឹកប្រាក់ដែលទទួលបានមុនពេលព្រឹត្តិការណ៍ជាប់ពន្ធ ក៏អាចកើតឡើងពាក់ព័ន្ធនឹងពន្ធផងដែរ។

## ការវិភាគលំហូរចូលដំបូងនៃធនធានពីប្រតិបត្តិការមិនដោះដូរ

២៩. ស្ថាប័ននឹងទទួលស្គាល់ទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរ នៅពេលដែលខ្លួនទទួលបានការកាន់កាប់លើធនធានដែលបំពេញតាមនិយមន័យនៃទ្រព្យសកម្ម និងបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់។ នៅក្នុងកាលៈទេសៈជាក់លាក់ ដូចជា នៅពេលដែលម្ចាស់បំណុលលើកលែងបំណុល, ការថយចុះតម្លៃយោងនៃបំណុលដែលបានទទួលស្គាល់ពីមុន អាចនឹងកើតមានឡើង។ ក្នុងករណីទាំងនេះ ជំនួសឱ្យការទទួលស្គាល់ទ្រព្យសកម្ម, ស្ថាប័នបន្ថយតម្លៃយោងនៃបំណុល។ នៅក្នុងករណីមួយចំនួនទៀត ការទទួលបានការគ្រប់គ្រងលើទ្រព្យសកម្ម ក៏អាចភ្ជាប់មកជាមួយនូវកាតព្វកិច្ចដែលស្ថាប័ននឹងទទួលស្គាល់ជាបំណុលផងដែរ។ វិភាគទានពីម្ចាស់ មិនបង្កើតឱ្យមានជាចំណូលនោះទេ ដូចនេះ ប្រភេទប្រតិបត្តិការនីមួយៗត្រូវបានវិភាគ ហើយរាល់វិភាគទានពីម្ចាស់ត្រូវបានទទួលស្គាល់ដាច់ដោយឡែក។ ដោយមានសង្គតិភាពជាមួយនឹងវិធីសាស្ត្រដែលបានកំណត់នៅក្នុងស្តង់ដានេះ ស្ថាប័ននឹងធ្វើការវិភាគប្រតិបត្តិការមិនដោះដូរ ដើម្បីកំណត់ថាតើធាតុណាមួយនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ នឹងត្រូវបានទទួលស្គាល់ជាលទ្ធផលនៃប្រតិបត្តិការ។ ប្លង់លំហូរការងារនៅទំព័របន្ទាប់ បង្ហាញអំពីដំណើរការវិភាគដែលស្ថាប័នបានអនុវត្ត នៅពេលមានលំហូរចូលនៃធនធាន ដើម្បីកំណត់ថាតើមានចំណូលបានកើតឡើងដែរឬទេ។ ស្តង់ដានេះអនុវត្តតាមរចនាសម្ព័ន្ធនៃប្លង់លំហូរការងារ។ លក្ខខណ្ឌចាំបាច់សម្រាប់ប្រព្រឹត្តិកម្មនៃប្រតិបត្តិការ ត្រូវបានកំណត់នៅក្នុងកថាខណ្ឌ ៣០-១១៥។

## ការបង្ហាញអំពីការវិភាគលំហូរចូលដំបូងនៃធនធាន (១.)




(១.) ប្លង់លំហូរការងារនេះ គឺសម្រាប់បង្ហាញតែប៉ុណ្ណោះ ដោយមិនបានជំនួសឱ្យស្តង់ដានេះទេ។ ប្លង់លំហូរការងារនេះ ត្រូវបានផ្តល់ជូនជាជំនួយក្នុងការបកស្រាយស្តង់ដានេះ។

(២.) នៅក្នុងកាលៈទេសៈជាក់លាក់ដូចជា នៅពេលដែលម្ចាស់បំណុលលើកលែងបំណុល ការថយចុះតម្លៃយោងនៃបំណុលដែលបានទទួលស្គាល់ពីមុន អាចនឹងកើតមានឡើង។ ក្នុងករណីនេះ ជំនួសឱ្យការទទួលស្គាល់ទ្រព្យសកម្ម ស្ថាប័នបន្ថយតម្លៃយោងនៃបំណុល។

(៣.) ក្នុងការកំណត់ថាតើស្ថាប័នបានបំពេញកាតព្វកិច្ចបច្ចុប្បន្នទាំងអស់ដែរឬទេ, ការអនុវត្តនិយមន័យនៃលក្ខខណ្ឌលើទ្រព្យ-សកម្មដែលបានផ្ទេរ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់បំណុល ត្រូវបានពិចារណា។

## ការទទួលស្គាល់ទ្រព្យសកម្ម

៣០. ទ្រព្យសកម្មត្រូវបានកំណត់នៅក្នុងស្តង់ដា CPSAS 1 ថាជាធនធានដែលត្រូវបានគ្រប់គ្រងដោយស្ថាប័ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍នាពេលអតីត ហើយអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដែលចេញពីធនធានទាំងនោះ ត្រូវបានរំពឹងថានឹងហូរចូលស្ថាប័ន។

**៣១. លំហូរចូលនៃធនធានពីប្រតិបត្តិការមិនដោះដូរ ជាជាងសេវាដែលបានពីការបរិច្ចាគដែលបំពេញតាមនិយមន័យនៃទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម នៅពេល និងតែនៅពេល÷**

**(ក) វាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដែលពាក់ព័ន្ធនឹងទ្រព្យសកម្ម នឹងហូរចូលស្ថាប័ន និង**

**(ខ) តម្លៃសមស្របនៃទ្រព្យសកម្ម អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។**

## ការគ្រប់គ្រងទ្រព្យសកម្ម

៣២. សមត្ថភាពក្នុងការដកចេញ ឬ គ្រប់គ្រងសិទ្ធិរបស់អ្នកដទៃដើម្បីទទួលបានអត្ថប្រយោជន៍នៃទ្រព្យសកម្ម គឺជាធាតុដ៏សំខាន់មួយនៃការគ្រប់គ្រង ដែលញែកទ្រព្យសកម្មរបស់ស្ថាប័ន ពីទំនិញសាធារណៈទាំងឡាយណាដែលស្ថាប័នទាំងអស់មានសិទ្ធិក្នុងការប្រើប្រាស់ និងទទួលបានផលប្រយោជន៍។ ក្នុងវិស័យសាធារណៈ រាជរដ្ឋាភិបាលអនុវត្តតួនាទីជានិយ័តករគ្រប់គ្រងលើសកម្មភាពជាក់លាក់មួយចំនួន ឧទាហរណ៍ ដូចជា គ្រឹះស្ថានហិរញ្ញវត្ថុ ឬ មូលនិធិសោធននិវត្តន៍។ តួនាទីជានិយ័តករនេះ មិនមែនមានន័យថា ធាតុដែលត្រូវបានគ្រប់គ្រងទាំងនោះ បំពេញតាមនិយមន័យនៃទ្រព្យសកម្មរបស់រាជរដ្ឋាភិបាល ឬបំពេញតាមលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរបស់រាជរដ្ឋាភិបាលដែលគ្រប់គ្រងទ្រព្យសកម្មទាំងនោះទេ។ អនុលោមតាមកថាខណ្ឌ ៩៨, ស្ថាប័នអាច ប៉ុន្តែមិនត្រូវបានតម្រូវឱ្យទទួលស្គាល់សេវាដែលបានពីការបរិច្ចាគនោះទេ។

៣៣. ការប្រកាសអំពីបំណងក្នុងការផ្ទេរធនធានទៅកាន់ស្ថាប័នសាធារណៈ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេក្នុងការកំណត់ថា ធនធានត្រូវបានគ្រប់គ្រងដោយអ្នកទទួលផល។ ឧទាហរណ៍ ប្រសិនបើសាលារៀនរដ្ឋត្រូវបានបំផ្លាញដោយភ្លើងឆេះព្រៃ ហើយរាជរដ្ឋាភិបាលបានប្រកាសអំពីបំណងរបស់ខ្លួនក្នុងការផ្ទេរមូលនិធិដើម្បីសាងសង់សាលារៀនឡើងវិញ សាលារៀននឹងមិនទទួលស្គាល់លំហូរចូលនៃធនធាន(ធនធានដែលត្រូវទទួល) នៅពេលប្រកាសនោះទេ។ ក្នុងកាលៈទេសៈដែលកិច្ចព្រមព្រៀងនៃការផ្ទេរត្រូវបានតម្រូវមុនពេលដែលធនធានអាចត្រូវបានផ្ទេរ ស្ថាប័នដែលជាអ្នកទទួលផល នឹងមិនកំណត់ធនធានថាត្រូវបានគ្រប់គ្រងនោះទេ រហូតដល់ពេលដែលកិច្ចព្រមព្រៀងត្រូវបានចងជាកាតព្វកិច្ចអនុវត្ត ពីព្រោះស្ថាប័នដែលជាអ្នកទទួលផល មិនអាចដកចេញ ឬ គ្រប់គ្រងសិទ្ធិរបស់អ្នកផ្ទេរដើម្បីទទួលបានធនធាននោះទេ។ ក្នុងករណីភាគច្រើន ស្ថាប័ននឹងចាំបាច់ត្រូវបង្កើតភាពអាចចាប់បង្ខំឱ្យអនុវត្តនៃការគ្រប់គ្រងធនធានរបស់ខ្លួន មុនពេលដែលខ្លួនអាចទទួលស្គាល់ជាទ្រព្យសកម្មបាន។ ប្រសិនបើស្ថាប័នមិនមានសិទ្ធិទាមទារធនធានទាំងនោះទេ, ស្ថាប័នមិនអាចដកចេញ ឬ គ្រប់គ្រងសិទ្ធិរបស់អ្នកផ្ទេរដើម្បីទទួលបានធនធានទាំងនោះទេ។

**ព្រឹត្តិការណ៍នាពេលអតីត**

៣៤. ស្ថាប័នសាធារណៈ ជាធម្មតាទទួលបានទ្រព្យសកម្មពីរាជរដ្ឋាភិបាល ស្ថាប័នផ្សេងទៀត រួមទាំងអ្នកជាប់ពន្ធ ឬ តាមរយៈការទិញ ឬ ការផលិតទ្រព្យសកម្មទាំងនោះ។ ដូចនេះ ព្រឹត្តិការណ៍នាពេលអតីតដែលបង្កើតឱ្យមានការគ្រប់គ្រងទ្រព្យសកម្ម អាចជាការទិញ, ព្រឹត្តិការណ៍ជាប់ពន្ធ ឬ ការផ្ទេរ។ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ដែលរំពឹងថានឹងកើតឡើងនាពេលអនាគត មិនបង្កើតឱ្យមាននូវទ្រព្យសកម្មនោះទេ ដូចនេះ ឧទាហរណ៍ បំណងដើម្បីកំណត់ពន្ធ មិនមែនជាព្រឹត្តិការណ៍នាពេលអតីតដែលបង្កើតឱ្យមាននូវទ្រព្យសកម្មក្នុងទម្រង់ជាសិទ្ធិទាមទារចំពោះអ្នកជាប់ពន្ធនោះទេ។

**លំហូរចូលនៃធនធានដែលអាចនឹងកើតមានឡើង**

៣៥. លំហូរចូលនៃធនធាន អាចនឹងកើតមានឡើង នៅពេលលំហូរចូលទំនងជាកើតមានឡើង។ ស្ថាប័នយកការកំណត់នេះ ដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍នាពេលអតីតរបស់ខ្លួន ជាមួយនឹងប្រភេទនៃលំហូរធនធានប្រហាក់ប្រហែល និងការរំពឹងទុករបស់ខ្លួន ពាក់ព័ន្ធនឹងអ្នកជាប់ពន្ធ ឬ អ្នកផ្ទេរ។ ឧទាហរណ៍ នៅពេលដែល (ក) រាជរដ្ឋាភិបាលយល់ព្រមផ្ទេរមូលនិធិទៅកាន់ស្ថាប័នសាធារណៈ (ស្ថាប័នរាយការណ៍), (ខ) កិច្ចព្រមព្រៀងត្រូវបានចងជាកាតព្វកិច្ចត្រូវអនុវត្ត, និង (គ) រាជរដ្ឋាភិបាលធ្លាប់មានប្រវត្តិផ្ទេរធនធានដែលបានព្រមព្រៀងគ្នា, វាអាចនឹងកើតមានឡើងដែលលំហូរចូលនឹងកើតមានឡើង បើទោះបីជាមូលនិធិមិនទាន់ត្រូវបានផ្ទេរនាកាលបរិច្ឆេទរាយការណ៍ក៏ដោយ។

**ទ្រព្យសកម្មយថាហេតុ**

៣៦. ធាតុមួយដែលមានបុគ្គលិកលក្ខណៈសំខាន់ៗជាទ្រព្យសកម្ម ប៉ុន្តែមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ អាចធានាបានដោយលាតត្រដាងក្នុងកំណត់សម្គាល់ថាជាទ្រព្យសកម្មយថាហេតុ (សូមមើលស្តង់ដា CPSAS 19)។

**វិភាគទានពីម្ចាស់**

៣៧. វិភាគទានពីម្ចាស់ ត្រូវបានកំណត់នៅក្នុងស្តង់ដា CPSAS 1។ សម្រាប់ប្រតិបត្តិការមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាវិភាគទានពីម្ចាស់ ចាំបាច់ត្រូវបំពេញតាមបុគ្គលិកលក្ខណៈដូចបានកំណត់នៅក្នុងនិយមន័យនោះ។ ក្នុងការកំណត់ថាតើប្រតិបត្តិការមួយ បំពេញតាមនិយមន័យនៃវិភាគទានពីម្ចាស់ដែរទេ, ភាពជាក់ស្តែង ជាជាងទម្រង់នៃប្រតិបត្តិការនោះ ត្រូវបានពិចារណា។ កថាខណ្ឌ ៣៨ បង្ហាញអំពីទម្រង់នៃវិភាគទានពីម្ចាស់។ ទោះបីជាប្រតិបត្តិការមានទម្រង់បែបណាក៏ដោយ ប្រសិនបើភាពជាក់ស្តែងមានទម្រង់ជាកម្ចី ឬ ប្រភេទបំណុលផ្សេងទៀត ឬ ចំណូល, ស្ថាប័ននឹងទទួលស្គាល់ជាវិភាគទានពីម្ចាស់ ហើយនឹងធ្វើការលាតត្រដាងយ៉ាងសមស្របក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ប្រសិនបើមានភាពជាសារវន្ត។ ឧទាហរណ៍ ប្រសិនបើប្រតិបត្តិការមួយមើលទៅហាក់ដូចជាវិភាគទានពីម្ចាស់ ប៉ុន្តែកំណត់ថា ស្ថាប័នរាយការណ៍នឹងទូទាត់ការបែងចែកថេរទៅកាន់អ្នកផ្ទេរ ជាមួយព្រាក់ចំណេញពីការវិនិយោគរបស់អ្នកផ្ទេរ នាពេលវេលាដែលបានកំណត់មួយនាពេលអនាគត, ប្រតិបត្តិការនេះកាន់តែ

មានបុគ្គលិកលក្ខណៈជាប្រាក់កម្ចី។ សម្រាប់កិច្ចសម្រុះសម្រួលនៃកិច្ចសន្យា ស្ថាប័នក៏អាចពិចារណាលើការណែនាំនៅក្នុងស្តង់ដា CPSAS 28, ឧបករណ៍ហិរញ្ញវត្ថុ÷ការដាក់បង្ហាញ នៅពេលធ្វើការញែកបំណុលចេញពីវិភាគទានពីម្ចាស់។

៣៨. វិភាគទានពីម្ចាស់ អាចត្រូវបានផ្តល់ភស្តុតាងតាមរយៈ ឧទាហរណ៍÷

(ក) ការជ្រើសរើសទុកមុនជាផ្លូវការនៃការផ្ទេរ (ឬ ថ្នាក់នៃការផ្ទេរបែបនេះ) ដោយអ្នកចូលរួមវិភាគទាន ឬ ស្ថាប័នគ្រប់គ្រងរបស់អ្នកចូលរួមវិភាគទាន ជាការចូលរួមចំណែកជាផ្នែកមួយនៃទ្រព្យសកម្ម/មូលធនសុទ្ធដែលបានចូលរួមវិភាគទានពីអ្នកទទួលផល មុនពេលដែលវិភាគទានកើតឡើង ឬ នៅពេលចូលរួមវិភាគទាន។

(ខ) កិច្ចព្រមព្រៀងជាផ្លូវការ ពាក់ព័ន្ធនឹងវិភាគទាន ដែលបង្កើត ឬ បង្កើនអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុដែលមានស្រាប់នៅក្នុងទ្រព្យសកម្ម/មូលធនសុទ្ធរបស់អ្នកទទួលផល ដែលអាចលក់ ផ្ទេរ ឬផ្តល់សំណង ឬ

(គ) ការបោះផ្សាយ ពាក់ព័ន្ធនឹងវិភាគទាននៃឧបករណ៍មូលធន ដែលអាចលក់ ផ្ទេរ ឬ ផ្តល់សំណង។

## សមាសធាតុដោះដូរ និងសមាសធាតុមិនដោះដូរនៃប្រតិបត្តិការមួយ

៣៩. កថាខណ្ឌ ៤០ និង កថាខណ្ឌ ៤១ ខាងក្រោម បង្ហាញពីកាលៈទេសៈដែលស្ថាប័នទទួលបានការគ្រប់គ្រងលើធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ជាជាងតាមរយៈវិភាគទានពីម្ចាស់។

៤០. កថាខណ្ឌ ១១ នៃស្តង់ដា CPSAS 9 កំណត់អំពីប្រតិបត្តិការដោះដូរ និងប្រតិបត្តិការមិនដោះដូរ ហើយកថាខណ្ឌ ១០ នៃស្តង់ដានេះ កត់សម្គាល់ថា ប្រតិបត្តិការមួយអាចរួមបញ្ចូលនូវសមាសធាតុចំនួនពីរ គឺសមាសធាតុដោះដូរ និងសមាសធាតុមិនដោះដូរ។

៤១. នៅពេលដែលទ្រព្យសកម្មត្រូវបានទិញ តាមមធ្យោបាយនៃប្រតិបត្តិការដែលមានសមាសធាតុដោះដូរ និងសមាសធាតុមិនដោះដូរ ស្ថាប័នទទួលស្គាល់សមាសធាតុដោះដូរ ដោយយោងតាមគោលការណ៍ និងលក្ខខណ្ឌចាំបាច់នៃស្តង់ដា CPSASs ផ្សេងទៀត។ សមាសធាតុមិនដោះដូរ ត្រូវបានទទួលស្គាល់ ដោយយោងតាមគោលការណ៍ និងលក្ខខណ្ឌចាំបាច់នៃស្តង់ដានេះ។ ក្នុងការកំណត់ថាតើប្រតិបត្តិការមួយមានសមាសធាតុដោះដូរ និងសមាសធាតុមិនដោះដូរដែលអាចញែកដាច់ពីគ្នាបាន, ការវិនិច្ឆ័យបែបវិជ្ជាជីវៈត្រូវបានអនុវត្ត។ នៅក្នុងករណីដែលមិនអាចញែកបានរវាងសមាសធាតុដោះដូរនិងសមាសធាតុមិនដោះដូរ, ប្រតិបត្តិការត្រូវបានចាត់ទុកជាប្រតិបត្តិការមិនដោះដូរ។

## ការវាស់វែងទ្រព្យសកម្មនាការទទួលស្គាល់លើកដំបូង

**៤២. ទ្រព្យសកម្មដែលបានទិញតាមរយៈប្រតិបត្តិការមិនដោះដូរ ត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃការទិញ។**

៤៣. ដោយមានសង្គតិភាពជាមួយនឹងស្តង់ដា CPSAS 12 សន្និធិ, CPSAS 16 ទ្រព្យវិនិយោគ និង CPSAS 17 ទ្រព្យ, រោងចក្រ និងបរិក្ខារ និង CPSAS 41 ឧបករណ៍ហិរញ្ញវត្ថុ, ទ្រព្យសកម្មដែលត្រូវបានទិញតាមរយៈប្រតិបត្តិការមិនដោះដូរ ត្រូវវាស់វែងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃការទិញ។

## ការទទួលស្គាល់ចំណូលពីប្រតិបត្តិការមិនដោះដូរ

**៤៤. លំហូរចូលនៃធនធានពីប្រតិបត្តិការមិនដោះដូរដែលត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ជាចំណូល លើកលែងតែក្នុងវិសាលភាពដែលបំណុលក៏ត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងលំហូរចូលដូចគ្នា។**

**៤៥. ខណៈដែលស្ថាប័នបំពេញនូវកាតព្វកិច្ចបច្ចុប្បន្នដែលត្រូវបានទទួលស្គាល់ជាបំណុល ពាក់ព័ន្ធនឹងលំហូរចូលនៃធនធានពីប្រតិបត្តិការមិនដោះដូរដែលត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ស្ថាប័នត្រូវកាត់បន្ថយតម្លៃយោងនៃបំណុលដែលត្រូវបានទទួលស្គាល់ ហើយទទួលស្គាល់ចំនួនទឹកប្រាក់នៃចំណូល ឱ្យស្មើនឹងការកាត់បន្ថយនោះ។**

៤៦. នៅពេលស្ថាប័នទទួលស្គាល់នូវការកើនឡើងនៃទ្រព្យសកម្មសុទ្ធ ដែលជាលទ្ធផលនៃប្រតិបត្តិការមិនដោះដូរ ស្ថាប័នទទួលស្គាល់ជាចំណូល។ ប្រសិនបើស្ថាប័នបានទទួលស្គាល់ជាបំណុល ពាក់ព័ន្ធនឹងលំហូរចូលនៃធនធានដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរ នៅពេលដែលបំណុលត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ដោយសារព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង ឬ លក្ខខណ្ឌត្រូវបានបំពេញ, ស្ថាប័នទទួលស្គាល់ជាចំណូល។ ប្រសិនបើលំហូរចូលនៃធនធាន បំពេញតាមនិយមន័យនៃវិភាគទានពីម្ចាស់, លំហូរចូលនៃធនធាននោះមិនត្រូវបានទទួលស្គាល់ជាបំណុល ឬ ចំណូលនោះទេ។

៤៧. ពេលវេលានៃការទទួលស្គាល់ចំណូល ត្រូវបានកំណត់ដោយចរិតលក្ខណៈនៃលក្ខខណ្ឌ និងការទូទាត់នៃចំណូលទាំងនោះ។ ឧទាហរណ៍ ប្រសិនបើលក្ខខណ្ឌបានកំណត់ថា ស្ថាប័នត្រូវផ្តល់ទំនិញ ឬ សេវាទៅកាន់ភាគីទីបី ឬ ប្រគល់មូលនិធិដែលមិនបានប្រើប្រាស់ទៅឱ្យអ្នកផ្ទេរវិញ, ចំណូលត្រូវបានទទួលស្គាល់នៅពេលទំនិញ ឬ សេវាត្រូវបានផ្តល់។

## ការវាស់វែងចំណូលពីប្រតិបត្តិការមិនដោះដូរ

**៤៨. ចំណូលដែលទទួលបានពីប្រតិបត្តិការមិនដោះដូរ ត្រូវបានវាស់វែងតាមចំនួននៃការកើនឡើងទ្រព្យសកម្មសុទ្ធដែលបានទទួលស្គាល់ដោយស្ថាប័ន។**

៤៩. ជាលទ្ធផលនៃប្រតិបត្តិការមិនដោះដូរ នៅពេលស្ថាប័នទទួលស្គាល់ទ្រព្យសកម្ម ស្ថាប័នក៏ត្រូវទទួលស្គាល់ចំណូលដែលសមមូលទៅនឹងចំនួនទឹកប្រាក់នៃទ្រព្យសកម្មដែលត្រូវបានវាស់វែង ដោយអនុលោមតាមកថាខណ្ឌ ៤២ ផងដែរ លើកលែងតែស្ថាប័នក៏ត្រូវបានតម្រូវឱ្យទទួលស្គាល់បំណុល។ នៅពេលបំណុលត្រូវបានតម្រូវឱ្យមានការទទួលស្គាល់ បំណុលនឹងត្រូវបានវាស់វែង ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ ៥៧ ហើយចំនួននៃការកើនឡើងទ្រព្យសកម្មសុទ្ធ ប្រសិនបើមាន នឹងត្រូវបានទទួលស្គាល់ជាចំណូល។ នៅពេលបំណុលត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ដោយសារព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង ឬ លក្ខខណ្ឌត្រូវបានបំពេញ, ចំនួននៃការកាត់បន្ថយបំណុលនោះនឹងត្រូវបានទទួលស្គាល់ជាចំណូល។

## ការតព្វកិច្ចបច្ចុប្បន្នដែលបានទទួលស្គាល់ជាបំណុល

៥០. **កាតព្វកិច្ចបច្ចុប្បន្នដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរដែលបំពេញតាមនិយមន័យនៃបំណុល ត្រូវបានទទួលស្គាល់ជាបំណុល នៅពេល និងតែនៅពេល÷**

(ក) **វាអាចនឹងកើតមានឡើងដែល លំហូរចេញនៃធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត នឹងត្រូវបានតម្រូវដើម្បីទូទាត់កាតព្វកិច្ច និង**

(ខ) **ការប៉ាន់ស្មានដែលអាចជឿទុកចិត្តបាន អាចត្រូវបានធ្វើឡើងពីចំនួនទឹកប្រាក់នៃកាតព្វកិច្ច។**

## កាតព្វកិច្ចបច្ចុប្បន្ន

៥១. កាតព្វកិច្ចបច្ចុប្បន្ន គឺជាកាតព្វកិច្ចដែលត្រូវធ្វើសកម្មភាព ឬ អនុវត្តតាមវិធីជាក់លាក់មួយ ហើយអាចបង្កើតឱ្យមានបំណុលទាក់ទងនឹងប្រតិបត្តិការមិនដោះដូរ។ កាតព្វកិច្ចបច្ចុប្បន្ន អាចត្រូវបានកំណត់ដោយលក្ខន្តិកៈនៅក្នុងច្បាប់ ឬ បទប្បញ្ញត្តិ ឬ កិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្ត ដែលបង្កើតមូលដ្ឋាននៃការផ្ទេរ។ កាតព្វកិច្ចបច្ចុប្បន្ន ក៏អាចកើតឡើងពីបរិយាកាសប្រតិបត្តិការធម្មតា ដូចជា ការទទួលស្គាល់ចំណូលដែលទទួលបានមុន។

៥២. នៅក្នុងករណីជាច្រើន ពន្ធត្រូវបានកំណត់ ហើយទ្រព្យសកម្មត្រូវបានផ្ទេរទៅកាន់ស្ថាប័នសាធារណៈ ជាប្រតិបត្តិការមិនដោះដូរ ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ ឬ កិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្តផ្សេងទៀតដែលកំណត់អំពីលក្ខន្តិកៈ ដែលពន្ធនិងទ្រព្យសកម្មត្រូវបានប្រើសម្រាប់គោលបំណងជាក់លាក់។ ឧទាហរណ៍÷

(ក) ពន្ធ ដែលការប្រើប្រាស់ត្រូវបានកម្រិតដោយច្បាប់ ឬ បទប្បញ្ញត្តិ សម្រាប់គោលបំណងដែលបានកំណត់

(ខ) ការផ្ទេរ ដែលត្រូវបានបង្កើតឡើងដោយកិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្ត ដែលរួមបញ្ចូលនូវលក្ខខណ្ឌ÷

- (i) ពីរដ្ឋបាលថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- (ii) ពីរដ្ឋបាលថ្នាក់ខេត្ត ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- (iii) ពីរាជរដ្ឋាភិបាល ទៅស្ថាប័នសាធារណៈផ្សេងទៀត
- (iv) ទៅភ្នាក់ងាររាជរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយច្បាប់ ឬ បទប្បញ្ញត្តិ ដើម្បីអនុវត្តមុខងារជាក់លាក់ ជាមួយនឹងស្វ័យភាពប្រតិបត្តិការ ដូចជា អាជ្ញាធរច្បាប់ ឬ ក្រុមប្រឹក្សា ឬ អាជ្ញាធរប្រចាំតំបន់ និង
- (v) ពីភ្នាក់ងារម្ចាស់ជំនួយ ទៅរាជរដ្ឋាភិបាល ឬ ស្ថាប័នសាធារណៈផ្សេងទៀត។

៥៣. នៅក្នុងកិច្ចប្រតិបត្តិការធម្មតា ស្ថាប័នរាយការណ៍អាចទទួលយកធនធានមុនពេលព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង។ នៅក្នុងកាលៈទេសៈបែបនេះ បំណុលនៃចំនួនទឹកប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់នៃចំណូលដែលបានទទួលមុន ត្រូវបានទទួលស្គាល់ រហូតដល់ព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង។

៥៤. ប្រសិនបើស្ថាប័នរាយការណ៍មួយទទួលបានធនធាន មុនពេលមានកិច្ចសម្រុះសម្រួលនៃការផ្ទេរដែលចងកាតព្វកិច្ចអនុវត្តកើតឡើង, ស្ថាប័នរាយការណ៍ ទទួលស្គាល់បំណុលសម្រាប់ចំណូលដែលទទួលបានមុនរហូតដល់ពេលដែលកិច្ចសម្រុះសម្រួលត្រូវបានចងកាតព្វកិច្ចអនុវត្ត។

### លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ

៥៥. **លក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ បង្កើតឱ្យមានកាតព្វកិច្ចបច្ចុប្បន្ននាការទទួលស្គាល់លើកដំបូងដែលនឹងត្រូវបានទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ ៥០។**

៥៦. លក្ខន្តិកៈ ត្រូវបានកំណត់នៅក្នុងកថាខណ្ឌ ៧។ កថាខណ្ឌ ១៤-២៥ ផ្តល់ការណែនាំស្តីពីការកំណត់ថាតើលក្ខន្តិកៈ គឺជាលក្ខខណ្ឌ ឬ ការរឹតត្បិត។ ស្ថាប័នធ្វើការវិភាគទៅលើលក្ខន្តិកៈណាមួយ និងលក្ខន្តិកៈទាំងអស់ដែលភ្ជាប់ជាមួយនឹងលំហូរចូលនៃធនធាន ដើម្បីកំណត់ថាតើលក្ខន្តិកៈទាំងនោះកំណត់នូវលក្ខខណ្ឌ ឬ ការរឹតត្បិត។

### ការវាស់វែងបំណុលនាការទទួលស្គាល់លើកដំបូង

៥៧. **ចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ជាបំណុល ត្រូវតែជាការប៉ាន់ស្មានដ៏គួរឱ្យជឿជាក់នៃចំនួនទឹក-ប្រាក់ដែលត្រូវបានតម្រូវដើម្បីទូទាត់កាតព្វកិច្ចបច្ចុប្បន្ននាកាលបរិច្ឆេទរាយការណ៍។**

៥៨. ការប៉ាន់ស្មាន ត្រូវពិចារណាអំពីហានិភ័យ និងភាពមិនច្បាស់លាស់ដែលកើតមានឡើងជុំវិញព្រឹត្តិការណ៍ដែលបណ្តាលឱ្យបំណុលត្រូវបានទទួលស្គាល់។ នៅពេលដែលតម្លៃពេលវេលានៃប្រាក់ មានភាពជាសារវន្ត, បំណុលនឹងត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបានតម្រូវដើម្បីទូទាត់កាតព្វកិច្ច។ លក្ខខណ្ឌចាំបាច់នេះ គឺអនុលោមតាមគោលការណ៍ដែលត្រូវបានបង្កើតឡើងនៅក្នុងស្តង់ដា CPSAS 19។

### ពន្ធ

៥៩. **ស្ថាប័នត្រូវទទួលស្គាល់ទ្រព្យសកម្មដែលពាក់ព័ន្ធនឹងពន្ធ នៅពេលមានព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង ហើយលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ទ្រព្យសកម្ម ត្រូវបានបំពេញ។**

៦០. ធនធានដែលកើតឡើងពីពន្ធ បំពេញតាមនិយមន័យនៃទ្រព្យសកម្ម នៅពេលដែលស្ថាប័នគ្រប់គ្រងធនធានជាលទ្ធផលនៃព្រឹត្តិការណ៍នាពេលអតីត (ព្រឹត្តិការណ៍ជាប់ពន្ធ) ហើយរំពឹងថានឹងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ចេញពីធនធានទាំងនោះ។ ធនធានដែលកើតឡើងពីពន្ធបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្ម នៅពេលវាអាចនឹងកើតមានឡើងដែលលំហូរចូលនៃធនធាននឹងកើតឡើង ហើយតម្លៃសមស្របនៃធនធានទាំងនោះអាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។ កម្រិតនៃភាពដែលអាចនឹងកើតមានឡើងដែលភ្ជាប់ជាមួយនឹងលំហូរចូលនៃធនធាន ត្រូវបានកំណត់ដោយផ្អែកលើភស្តុតាងដែលមាន នៅពេលទទួលស្គាល់លើកដំបូង ដែលរួមបញ្ចូលប៉ុន្តែមិនត្រូវបានកម្រិតត្រឹមការលាតត្រដាងនៃព្រឹត្តិការណ៍ជាប់ពន្ធ ដោយអ្នកជាប់ពន្ធនោះទេ។

៦១. ចំណូលសារពើពន្ធ កើតឡើងតែសម្រាប់រាជរដ្ឋាភិបាលដែលកំណត់ពន្ធ ហើយមិនមែនសម្រាប់ស្ថាប័នផ្សេងទៀតទេ។ ឧទាហរណ៍ នៅពេលដែលរដ្ឋបាលថ្នាក់ជាតិកំណត់ពន្ធដែលត្រូវប្រមូលដោយរដ្ឋបាលសារពើពន្ធ, ទ្រព្យសកម្មនិងចំណូលត្រូវបានបង្គរនៅរាជរដ្ឋាភិបាល មិនមែននៅរដ្ឋបាលសារពើពន្ធនោះទេ។ លើសពីនេះ នៅពេលដែលរដ្ឋបាលថ្នាក់ជាតិកំណត់ពន្ធលើការលក់ ដែលចំណូលទាំងស្រុងពីពន្ធលើការលក់ដែលចំណូលនោះបានបញ្ជូនទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើការវិភាគជាប្រចាំ, រដ្ឋបាលថ្នាក់ជាតិទទួលស្គាល់ទ្រព្យសកម្មនិងចំណូលសម្រាប់ពន្ធ ហើយទទួលស្គាល់ការធ្លាក់ចុះនៃទ្រព្យ-សកម្មនិងចំណាយសម្រាប់ការផ្ទេរទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងទទួលស្គាល់ទ្រព្យសកម្មនិងចំណូលសម្រាប់ការផ្ទេរ។ នៅពេលដែលអង្គភាពតែមួយប្រមូលពន្ធជំនួសឱ្យអង្គភាពច្រើនផ្សេងទៀត ស្ថាប័ននោះកំពុងដើរតួជាភ្នាក់ងារមួយសម្រាប់ស្ថាប័នទាំងនោះ។ ឧទាហរណ៍ នៅពេលដែលរដ្ឋបាលសារពើពន្ធរបស់រដ្ឋ ប្រមូលពន្ធលើប្រាក់ចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ, រដ្ឋបាលសារពើពន្ធរបស់រដ្ឋ មិនទទួលស្គាល់ចំណូលពាក់ព័ន្ធនឹងពន្ធដែលបានប្រមូលទេ; ផ្ទុយទៅវិញ រដ្ឋបាលនីមួយៗដែលកំណត់ពន្ធ ត្រូវទទួលស្គាល់ទ្រព្យសកម្មនិងចំណូលពាក់ព័ន្ធនឹងពន្ធ។

៦២. ពន្ធ មិនបានបំពេញតាមនិយមន័យនៃវិភាគទានពីម្ចាស់ទេ ពីព្រោះការបង់ពន្ធមិនបានផ្តល់សិទ្ធិឱ្យអ្នកជាប់ពន្ធក្នុងការទទួលបាន (ក) ការបែងចែកអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតដោយស្ថាប័នក្នុងអំឡុងពេលនៃអាយុកាលរបស់ស្ថាប័ន ឬ (ខ) ការបែងចែកទ្រព្យសកម្មដែលនៅសល់បន្ទាប់ពីការទូទាត់បំណុល ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានរំសាយ។ ការបង់ពន្ធ ក៏មិនបានផ្តល់ឱ្យអ្នកជាប់ពន្ធនូវសិទ្ធិជាម្ចាស់នៅក្នុងរាជរដ្ឋាភិបាលដែលត្រូវបានលក់ ដោះដូរ ផ្ទេរ ឬ ទូទាត់សងនោះដែរ។

៦៣. ពន្ធ បំពេញតាមនិយមន័យនៃប្រតិបត្តិការមិនដោះដូរ ពីព្រោះអ្នកជាប់ពន្ធ ផ្ទេរធនធានទៅរាជរដ្ឋាភិបាលដោយពុំទទួលបានតម្លៃស្មើប្រហាក់ប្រហែលដោយផ្ទាល់ជាការដោះដូរ។ ខណៈអ្នកជាប់ពន្ធអាចទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយសង្គមជាច្រើនដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាល, គោលនយោ-បាយសង្គមទាំងនេះ មិនត្រូវបានផ្តល់ដោយផ្ទាល់ជាការដោះដូរជាតម្លៃតបស្នងសម្រាប់ការបង់ពន្ធនោះទេ។

៦៤. ដូចបានកត់សម្គាល់នៅក្នុងកថាខណ្ឌ ៥២, ពន្ធមួយចំនួនត្រូវបានកំណត់សម្រាប់គោលបំណងជាក់លាក់។ ប្រសិនបើរាជរដ្ឋាភិបាលត្រូវបានតម្រូវឱ្យទទួលស្គាល់បំណុលទាក់ទងនឹងលក្ខខណ្ឌណាមួយ ពាក់ព័ន្ធនឹងទ្រព្យសកម្មដែលត្រូវបានទទួលស្គាល់ជាលទ្ធផលនៃការកំណត់ពន្ធសម្រាប់គោលបំណងជាក់លាក់, រាជ-រដ្ឋាភិបាលមិនទទួលស្គាល់ជាចំណូលនោះទេ រហូតដល់លក្ខខណ្ឌត្រូវបានបំពេញ ហើយបំណុលត្រូវបានកាត់បន្ថយ។ ទោះបីជាយ៉ាងណា ក្នុងករណីភាគច្រើន ពន្ធដែលបានកំណត់សម្រាប់គោលបំណងជាក់លាក់មិនត្រូវបានរំពឹងថានឹងបង្កើតឱ្យមានបំណុលនោះទេ ព្រោះគោលបំណងជាក់លាក់មានចំនួនស្មើគ្នានឹងការរឹតត្បិត មិនមែនលក្ខខណ្ឌនោះទេ។

## ព្រឹត្តិការណ៍ជាប់ពន្ធ

៦៥. ប្រភេទពន្ធប្រហាក់ប្រហែលគ្នា ត្រូវបានកំណត់នៅក្នុងយុត្តាធិការជាច្រើន។ ស្ថាប័នរាយការណ៍វិភាគលើបទប្បញ្ញត្តិស្តីពីពន្ធក្នុងដែនយុត្តាធិការរបស់ខ្លួន ដើម្បីកំណត់អំពីព្រឹត្តិការណ៍ជាប់ពន្ធសម្រាប់ពន្ធផ្សេងៗដែលបានកំណត់។ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះនៅក្នុងច្បាប់ ឬ បទប្បញ្ញត្តិ, ជាទូទៅ ព្រឹត្តិការណ៍ជាប់ពន្ធ សម្រាប់÷

(ក) ពន្ធលើប្រាក់ចំណូល គឺជាចំណូលដែលរកបានពីប្រាក់ចំណូលជាប់ពន្ធ ក្នុងអំឡុងការិយបរិច្ឆេទសារពើពន្ធ តាមរយៈអ្នកជាប់ពន្ធ

(ខ) អាករលើតម្លៃបន្ថែម គឺជាការអនុវត្តសកម្មភាពជាប់អាករ ក្នុងអំឡុងការិយបរិច្ឆេទសារពើពន្ធតាមរយៈអ្នកជាប់ពន្ធ

(គ) ពន្ធលើទំនិញនិងសេវា គឺជាការទិញ ឬ លក់ទំនិញនិងសេវាដែលជាប់ពន្ធ ក្នុងអំឡុងការិយបរិច្ឆេទសារពើពន្ធ

(ឃ) កាតព្វកិច្ចគយ គឺជាលំហូរទំនិញ ឬ សេវាដែលត្រូវបង់ពន្ធគយ ឆ្លងកាត់ព្រំដែនគយ

(ង) កាតព្វកិច្ចមរណភាព គឺជាមរណភាពរបស់បុគ្គលម្នាក់ដែលមានទ្រព្យជាប់ពន្ធ និង

(ច) ពន្ធលើអចលនទ្រព្យ គឺជាថ្ងៃផុតកំណត់នៃកាលបរិច្ឆេទដែលពន្ធត្រូវបានកំណត់ ឬ ការិយបរិច្ឆេទដែលពន្ធត្រូវបានកំណត់ ប្រសិនបើពន្ធត្រូវបានកំណត់តាមការិយបរិច្ឆេទ។

## ចំណូលសារពើពន្ធដែលបានទទួលមុន

៦៦. អនុលោមតាមនិយមន័យនៃទ្រព្យសកម្ម បំណុល និងលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ៥៩, ធនធានសម្រាប់ពន្ធដែលបានទទួលមុនពេលការកើតឡើងនៃព្រឹត្តិការណ៍ជាប់ពន្ធ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម និងបំណុល (ចំណូលដែលទទួលបានមុន) ពីព្រោះ (ក) ព្រឹត្តិការណ៍ដែលបង្កើតឱ្យមាននូវសិទ្ធិរបស់ស្ថាប័នចំពោះពន្ធ មិនបានកើតឡើង; និង (ខ) លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ចំណូលសារពើពន្ធ មិនត្រូវបានបំពេញ (សូមមើលកថាខណ្ឌ ៥៩) បើទោះបីជាស្ថាប័នបានទទួលលំហូរចូលនៃធនធានរួចហើយក៏ដោយ។ ចំណូលដែលទទួលបានមុនពាក់ព័ន្ធនឹងពន្ធ មិនមានភាពខុសគ្នាច្រើនពីចំណូលដែលទទួលបានមុនផ្សេងទៀតនោះទេ ដូចនេះ បំណុលត្រូវបានទទួលស្គាល់រហូតដល់ព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង។ នៅពេលព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង, បំណុលត្រូវបានទូទាត់សងរួច ហើយចំណូលត្រូវបានទទួលស្គាល់។

## ការវាស់វែងទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធ

៦៧. កថាខណ្ឌ ៤២ តម្រូវថា ទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធ ត្រូវបានវាស់វែងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃការទិញ។ ទ្រព្យសកម្មដែលកើតមានឡើងពីប្រតិបត្តិការសារពើពន្ធ ត្រូវបានវាស់វែងតាមការប៉ាន់ស្មានដ៏គួរឱ្យជឿជាក់នៃលំហូរចូលនៃធនធានទៅកាន់ស្ថាប័ន។ ស្ថាប័នរាយការណ៍នឹងរៀបចំគោលនយោបាយគណនេយ្យ សម្រាប់ការវាស់វែងទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការ

សារពើពន្ធ ដែលអនុលោមតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ៤២។ គោលនយោបាយគណនេយ្យសម្រាប់ការប៉ាន់ស្មានទ្រព្យសកម្មទាំងនេះ នឹងត្រូវពិចារណាលើភាពដែលអាចនឹងកើតមានឡើងដែលធនធានដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធនឹងហូរចូលរាជរដ្ឋាភិបាល ព្រមទាំងតម្លៃសមស្របនៃទ្រព្យសកម្មដែលកើតឡើង។

៦៨. នៅពេលមានការញែកដាច់ដោយឡែកពីគ្នារវាងពេលវេលានៃព្រឹត្តិការណ៍ជាប់ពន្ធ និងការប្រមូលពន្ធ, ស្ថាប័នសាធារណៈអាចវាស់វែងដោយជឿទុកចិត្តនូវទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធដោយប្រើ ឧទាហរណ៍ គំរូស្ថិតិ ផ្អែកលើប្រវត្តិនៃការប្រមូលពន្ធជាក់លាក់ នៅក្នុងការិយបរិច្ឆេទមុនៗ។ គំរូទាំងនេះនឹងរួមបញ្ចូលនូវការពិចារណាអំពីពេលវេលានៃចំណូលសាច់ប្រាក់ពីអ្នកជាប់ពន្ធ, ការប្រកាសពន្ធដែលធ្វើឡើងដោយអ្នកជាប់ពន្ធ និងទំនាក់ទំនងនៃចំនួនទឹកប្រាក់ពន្ធដែលត្រូវទទួល ជាមួយព្រឹត្តិការណ៍ផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច។ គំរូនៃការវាស់វែង ក៏នឹងត្រូវពិចារណាលើកត្តាផ្សេងទៀតផងដែរ ដូចជា÷

(ក) បទប្បញ្ញត្តិស្តីពីពន្ធដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធមានរយៈពេលយូរជាងមុន ក្នុងការដាក់លិខិតប្រកាសសារពើពន្ធ ច្រើនជាងរាជរដ្ឋាភិបាលត្រូវបានអនុញ្ញាតសម្រាប់ការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ

(ខ) អ្នកជាប់ពន្ធ មិនបានដាក់លិខិតប្រកាសសារពើពន្ធឱ្យបានទាន់ពេលវេលា

(គ) ការវាយតម្លៃទ្រព្យសកម្មមិនមែនរូបិយវត្ថុ សម្រាប់គោលបំណងវាយតម្លៃពន្ធ

(ឃ) ភាពស្មុគស្មាញនៃបទប្បញ្ញត្តិស្តីពីពន្ធដែលតម្រូវឱ្យមានរយៈពេលបន្ថែម សម្រាប់វាយតម្លៃពន្ធដែលដល់ពេលត្រូវបង់ដោយអ្នកជាប់ពន្ធជាក់លាក់

(ង) សក្តានុពលដែលចំណាយហិរញ្ញវត្ថុ និងចំណាយផ្នែកនយោបាយនៃការពង្រឹងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធយ៉ាងតឹងរ៉ឹង និងការប្រមូលពន្ធទាំងអស់ដែលដល់ពេលត្រូវបង់ដោយស្របច្បាប់ទៅកាន់រាជរដ្ឋាភិបាល អាចលើសអត្ថប្រយោជន៍ដែលទទួលបាន

(ច) បទប្បញ្ញត្តិស្តីពីពន្ធដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធពន្យារការបង់ពន្ធមួយចំនួន និង

(ឆ) កាលៈទេសៈជាច្រើនផ្សេងទៀត ទៅតាមប្រភេទពន្ធ និងយុត្តាធិការនីមួយៗ។

៦៩. ការវាស់វែងទ្រព្យសកម្មនិងចំណូលដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធ ដោយប្រើគំរូស្ថិតិ អាចបង្កើតឱ្យមានចំនួនទឹកប្រាក់ជាក់ស្តែងនៃទ្រព្យសកម្មនិងចំណូលដែលបានទទួលស្គាល់ ខុសគ្នាពីចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងការិយបរិច្ឆេទរាយការណ៍ជាបន្តបន្ទាប់ ដែលអ្នកជាប់ពន្ធត្រូវបង់ពាក់ព័ន្ធនឹងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន។ ការកែតម្រូវឡើងវិញលើការប៉ាន់ស្មាន ត្រូវបានធ្វើឡើងដោយអនុលោមតាមស្តង់ដា CPSAS 3 គោលនយោបាយគណនេយ្យ, ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង។

៧០. ក្នុងករណីមួយចំនួន ទ្រព្យសកម្មដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធនិងចំណូលពាក់ព័ន្ធ មិនអាចត្រូវបានវាស់វែងដោយជឿទុកចិត្តបានទេ រហូតដល់ក្រោយពេលមួយដែលព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង។ ករណីនេះអាចកើតឡើង ប្រសិនបើមូលដ្ឋានពន្ធ មានការប្រែប្រួលឆាប់រហ័ស និងការប៉ាន់ស្មានដែលអាច

ជឿទុកចិត្ត មិនអាចធ្វើទៅបាន។ ក្នុងករណីជាច្រើន ទ្រព្យសកម្មនិងចំណូលអាចត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ក្រោយការកើតឡើងនៃព្រឹត្តិការណ៍ជាប់ពន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ មានកាលៈទេសៈលើកលែងមួយចំនួន នៅពេលដែលការិយបរិច្ឆេទរាយការណ៍មួយចំនួននឹងកន្លងហួសមុនពេលដែលព្រឹត្តិការណ៍ជាប់ពន្ធបង្កើតឱ្យមានលំហូរចូលនៃធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ដែលបំពេញតាមនិយមន័យនៃទ្រព្យសកម្មនិងបំពេញតាមលក្ខណៈ-វិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្ម។ ឧទាហរណ៍ វាអាចត្រូវការពេលច្រើនឆ្នាំដើម្បីកំណត់និងវាស់វែងដោយជឿទុកចិត្តនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចមរណភាពដែលត្រូវបង់ ពាក់ព័ន្ធទៅនឹងទ្រព្យធំៗរបស់បុគ្គលដែលបានទទួលមរណភាព ពីព្រោះទ្រព្យទាំងនោះរួមបញ្ចូលនូវវត្ថុបុរាណនិងស្នាដៃសិល្បៈដ៏មានតម្លៃជាច្រើន ដែលទាមទារឱ្យមានការវាយតម្លៃពីអ្នកជំនាញ។ ដូចនេះ លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ ប្រហែលជាមិនត្រូវបានបំពេញនោះទេ រហូតដល់ការទូទាត់ត្រូវបានទទួល ឬ ត្រូវទទួល។

**ចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធ និងចំណាយសារពើពន្ធ**

៧១. **ចំណូលសារពើពន្ធ នឹងត្រូវកំណត់ជាចំនួនទឹកប្រាក់ដុល។ ចំណូលសារពើពន្ធ នឹងមិនត្រូវបានកាត់បន្ថយសម្រាប់ចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធនោះទេ។**

៧២. ក្នុងយុត្តាធិការមួយចំនួន រាជរដ្ឋាភិបាលប្រើប្រព័ន្ធពន្ធជាមធ្យោបាយដ៏ងាយស្រួលក្នុងការទូទាត់ ទៅអ្នកជាប់ពន្ធនូវអត្ថប្រយោជន៍ដែលនឹងត្រូវទូទាត់ដោយប្រើវិធីសាស្ត្រទូទាត់ផ្សេងទៀត ដូចជា ការសរសេរមូលប្បទានបត្រ, ការតម្កល់ចំនួនទឹកប្រាក់ដោយផ្ទាល់ទៅក្នុងគណនីធនាគាររបស់អ្នកជាប់ពន្ធ ឬការទូទាត់សងគណនីផ្សេងទៀតជំនួសឱ្យអ្នកជាប់ពន្ធ។ ឧទាហរណ៍ រាជរដ្ឋាភិបាលអាចទូទាត់ផ្នែកមួយនៃបុព្វលាភធានារ៉ាប់រងសុខភាពរបស់ប្រជាពលរដ្ឋ ដើម្បីលើកទឹកចិត្តដល់ការទទួលយកការធានារ៉ាប់រងបែបនេះ ដោយកាត់បន្ថយបំណុលពន្ធរបស់បុគ្គល, ការទូទាត់តាមរយៈមូលប្បទានបត្រ ឬ ដោយការទូទាត់ចំនួនទឹកប្រាក់ទៅក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។ នៅក្នុងករណីនេះ ចំនួនទឹកប្រាក់ គឺត្រូវបង់ ដោយមិនគិតថាតើបុគ្គលនោះបង់ពន្ធ ឬក៏អត់នោះទេ។ ជាលទ្ធផល ចំនួនទឹកប្រាក់នេះជាការចំណាយរបស់រាជរដ្ឋាភិបាល ហើយគួរត្រូវបានទទួលស្គាល់ដាច់ដោយឡែកនៅក្នុងរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ។ ចំណូលសារពើពន្ធគួរត្រូវបានបង្កើនសម្រាប់ចំនួនទឹកប្រាក់នៃចំណាយណាមួយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធ។

៧៣. **ចំណូលសារពើពន្ធ មិនត្រូវបានបូកសរុបដុលសម្រាប់ចំនួនទឹកប្រាក់នៃចំណាយសារពើពន្ធនោះទេ។**

៧៤. ក្នុងយុត្តាធិការភាគច្រើន រាជរដ្ឋាភិបាលប្រើប្រព័ន្ធពន្ធដើម្បីលើកទឹកចិត្តដល់ឥរិយាបទហិរញ្ញវត្ថុជាក់លាក់ និងមិនលើកទឹកចិត្តដល់ឥរិយាបទផ្សេងទៀត។ ឧទាហរណ៍ នៅក្នុងយុត្តាធិការមួយចំនួន ម្ចាស់លំនៅដ្ឋានត្រូវបានអនុញ្ញាតឱ្យកាត់កងការប្រាក់កម្ចី និងពន្ធលើអចលនទ្រព្យ ពីប្រាក់ចំណូលដុលរបស់ខ្លួន នៅពេលគណនាប្រាក់ចំណូលជាប់ពន្ធ។ ប្រភេទសម្បទានទាំងនេះមានសម្រាប់តែអ្នកជាប់ពន្ធប៉ុណ្ណោះ។ ប្រសិនបើស្ថាប័ន (រួមទាំងរូបវន្តបុគ្គល) មិនបានបង់ពន្ធ, ស្ថាប័នមិនអាចទទួលបានសម្បទាននោះទេ។ ប្រភេទសម្បទានទាំងនេះត្រូវបានហៅថា ចំណាយសារពើពន្ធ។ ចំណាយសារពើពន្ធ គឺជាចំណូលដែលមិនទទួលបាន, គឺមិនមែនជាចំណាយនោះទេ និងមិនបង្កើតឱ្យមានលំហូរចូល ឬ លំហូរចេញនៃធនធាន ពោលគឺ

ចំណាយសារពើពន្ធ មិនបង្កើតឱ្យមានទ្រព្យសកម្ម, បំណុល, ចំណូល ឬ ចំណាយរបស់រាជរដ្ឋាភិបាលដែលកំណត់ពន្ធនោះទេ។

៧៥. ភាពខុសគ្នាដ៏សំខាន់រវាងចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធនិងចំណាយសារពើពន្ធ គឺថា សម្រាប់ចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធ, ចំនួនទឹកប្រាក់នៃចំណាយនោះមានសម្រាប់អ្នកទទួលផលដោយមិនគិតថាតើអ្នកទទួលផល បង់ពន្ធ ឬ ក៏អត់នោះទេ ឬ ប្រើប្រាស់យន្តការជាក់លាក់មួយដើម្បីបង់ពន្ធរបស់ខ្លួន។ ស្តង់ដា CPSAS 1 ហាមឃាត់ក្នុងការកាត់កងធាតុនៃចំណូលនិងចំណាយ លើកលែងតែមានការអនុញ្ញាតពីស្តង់ដាផ្សេងទៀត។ ការកាត់កងចំណូលសារពើពន្ធ និងចំណាយដែលបានទូទាត់តាមរយៈប្រព័ន្ធពន្ធ មិនត្រូវបានអនុញ្ញាតឡើយ។

**ការផ្ទេរ**

៧៦. **យោងតាមកថាខណ្ឌ ៩៨, ស្ថាប័នត្រូវទទួលស្គាល់ទ្រព្យសកម្មពាក់ព័ន្ធនឹងការផ្ទេរ នៅពេលធនធានដែលបានផ្ទេរ បំពេញតាមនិយមន័យនៃទ្រព្យសកម្ម និងបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្ម។**

៧៧. ការផ្ទេរ រួមមាន អំណោយ, ការអនុគ្រោះបំណុល, ការផាកពិន័យ, អច្ច័យទាន, កាដូ, ការបរិច្ចាគ ព្រមទាំងទំនិញនិងសេវាដែលបានពីការបរិច្ចាគ។ ធាតុទាំងអស់នេះមានលក្ខណៈរួមដូចគ្នា ដែលផ្ទេរធនធានពីស្ថាប័នមួយទៅស្ថាប័នមួយទៀត ដោយមិនផ្តល់តម្លៃស្មើប្រហាក់ប្រហែល ជាការដោះដូរ ហើយមិនមែនជាពន្ធដូចបានកំណត់នៅក្នុងស្តង់ដានេះទេ។

៧៨. ការផ្ទេរ បំពេញតាមនិយមន័យនៃទ្រព្យសកម្ម នៅពេលដែលស្ថាប័នគ្រប់គ្រងធនធាន ជាលទ្ធផលនៃព្រឹត្តិការណ៍នាពេលអតីត (ការផ្ទេរ) ហើយរំពឹងថានឹងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគតពីធនធានទាំងនោះ។ ការផ្ទេរ បំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្ម នៅពេលដែលវាអាចនឹងកើតមានឡើងដែលលំហូរចូលនៃធនធាននឹងកើតមានឡើង ហើយតម្លៃសមស្របនៃធនធានទាំងនោះ អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។ ក្នុងស្ថានភាពជាក់លាក់ ដូចជានៅពេលម្ចាស់បំណុលលើកលែងបំណុល, ការថយចុះតម្លៃយោងនៃបំណុលដែលបានទទួលស្គាល់ពីមុនអាចនឹងកើតឡើង។ នៅក្នុងករណីទាំងនេះ ជំនួសឱ្យការទទួលស្គាល់ទ្រព្យសកម្មជាលទ្ធផលនៃការផ្ទេរ, ស្ថាប័នបន្ថយតម្លៃយោងនៃបំណុល។

៧៩. ស្ថាប័នទទួលបានការគ្រប់គ្រងលើធនធានដែលបានផ្ទេរ នៅពេលធនធានត្រូវបានផ្ទេរទៅកាន់ស្ថាប័ន ឬស្ថាប័នមានសិទ្ធិទាមទារដែលអាចចាប់បង្ខំអ្នកផ្ទេរឱ្យអនុវត្តបាន។ កិច្ចសម្រុះសម្រួលជាច្រើនក្នុងការផ្ទេរធនធាន ក្លាយជាការចងកាតព្វកិច្ចសម្រាប់គ្រប់ភាគីទាំងអស់ មុនពេលដែលការផ្ទេរធនធានកើតមានឡើង។ ទោះបីជាយ៉ាងណា ពេលខ្លះ ស្ថាប័នសន្យាផ្ទេរធនធាន ប៉ុន្តែមិនបានផ្ទេរនោះទេ។ ជាលទ្ធផល មានតែនៅពេលដែល (ក) សិទ្ធិទាមទារ អាចចាប់បង្ខំឱ្យអនុវត្ត ហើយ (ខ) ស្ថាប័នវាយតម្លៃថា វាអាចនឹងកើតមានឡើងដែលលំហូរចូលនៃធនធាននឹងកើតឡើង ដែលទ្រព្យសកម្ម បំណុល និង/ឬ ចំណូលនឹងត្រូវបាន

ទទួលស្គាល់។ រហូតដល់ពេលនោះ ស្ថាប័នមិនអាចដកចេញ ឬ គ្រប់គ្រងសិទ្ធិរបស់ភាគីទីបី ដើម្បីទទួលបានអត្ថប្រយោជន៍ពីធនធានដែលបានស្នើសម្រាប់ផ្ទេរ នោះទេ។

៨០. ការផ្ទេរធនធានដែលបំពេញតាមនិយមន័យនៃវិភាគទានពីម្ចាស់ នឹងមិនបង្កើតឱ្យមានចំណូលនោះទេ។ កិច្ចព្រមព្រៀង (ក) ដែលបញ្ជាក់ថា ស្ថាប័នដែលផ្តល់ធនធាន មានសិទ្ធិទទួលបានការបែងចែកនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ក្នុងអំឡុងពេលនៃអាយុកាលរបស់ស្ថាប័នដែលជាអ្នកទទួលផល ឬ ការបែងចែកទ្រព្យសកម្មណាមួយដែលលើស ក្រោយពីទូទាត់សងបំណុលរួចក្នុងករណីដែលស្ថាប័នជាអ្នកទទួលផល ទទួលរងការខាតបង់ ឬ (ខ) ដែលបញ្ជាក់ថា ស្ថាប័នដែលផ្តល់ធនធាន ទិញអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងស្ថាប័នដែលជាអ្នកទទួលផល ដែលអាចត្រូវបានលក់ដោះដូរ ផ្ទេរ ឬ ទូទាត់សង ជាខ្លឹមសារ គឺជាកិច្ចព្រមព្រៀងដើម្បីចូលរួមវិភាគទានពីម្ចាស់។

៨១. ការផ្ទេរ បំពេញតាមនិយមន័យនៃប្រតិបត្តិការមិនដោះដូរ ពីព្រោះអ្នកផ្ទេរផ្តល់ធនធានទៅកាន់ស្ថាប័នដែលជាអ្នកទទួលផល ដោយស្ថាប័នដែលជាអ្នកទទួលផល មិនបានផ្តល់តម្លៃស្មើប្រហាក់ប្រហែលដោយផ្ទាល់ជាការដោះដូរនោះទេ។ ប្រសិនបើកិច្ចព្រមព្រៀងមួយចែងថា ស្ថាប័នដែលជាអ្នកទទួលផល ត្រូវផ្តល់តម្លៃស្មើប្រហាក់ប្រហែលជាការដោះដូរ, កិច្ចព្រមព្រៀងនោះមិនមែនជាកិច្ចព្រមព្រៀងនៃការផ្ទេរទេ ប៉ុន្តែគឺជាកិច្ចសន្យាសម្រាប់ប្រតិបត្តិការដោះដូរដែលគួរត្រូវបានទទួលស្គាល់តាមស្តង់ដា CPSAS 9។

៨២. ស្ថាប័នធ្វើការវិភាគរាល់លក្ខន្តិកៈទាំងអស់ដែលមាននៅក្នុងកិច្ចព្រមព្រៀងនៃការផ្ទេរ ដើម្បីកំណត់ថាតើស្ថាប័នបង្កើតជាបំណុលដែរឬទេ នៅពេលស្ថាប័នទទួលយកធនធានដែលបានផ្ទេរ។

### ការវាស់វែងទ្រព្យសកម្មដែលបានផ្ទេរ

៨៣. ដូចបានតម្រូវនៅក្នុងកថាខណ្ឌ ៤២, ទ្រព្យសកម្មដែលបានផ្ទេរ ត្រូវបានវាស់វែងតាមតម្លៃសមស្រប នាកាលបរិច្ឆេទនៃការទិញ។ ស្ថាប័នរៀបចំគោលនយោបាយគណនេយ្យសម្រាប់ការទទួលស្គាល់ និងវាស់វែងទ្រព្យសកម្ម ដែលមានសង្គតិភាពជាមួយនឹងស្តង់ដា CPSASs។ ដូចបានកត់សម្គាល់ពីខាងដើម, សន្និធិ, ទ្រព្យ, រោងចក្រ, បរិក្ខារ ឬ ទ្រព្យវិនិយោគដែលបានទិញតាមរយៈប្រតិបត្តិការមិនដោះដូរ ត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃការទិញ ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដា CPSAS 12, CPSAS 16, និង CPSAS 17។ ឧបករណ៍ហិរញ្ញវត្ថុ ដែលរួមមាន សាច់ប្រាក់ និងការផ្ទេរដែលត្រូវទទួល ដែលបំពេញតាមនិយមន័យនៃឧបករណ៍ហិរញ្ញវត្ថុនិងទ្រព្យសកម្មផ្សេងទៀត ក៏នឹងត្រូវបានវាស់វែងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃការទិញ ដោយអនុលោមតាមកថាខណ្ឌ ៤២ និងគោលនយោបាយគណនេយ្យសមស្របផងដែរ។

### ការអនុគ្រោះបំណុល និងការសន្មតបំណុល

៨៤. ម្ចាស់បំណុល ពេលខ្លះ នឹងត្រូវលះបង់សិទ្ធិរបស់ខ្លួនក្នុងការប្រមូលបំណុលដែលបានជំពាក់ដោយស្ថាប័នសាធារណៈ ដោយធ្វើការលុបចោលបំណុល។ ឧទាហរណ៍ រដ្ឋបាលថ្នាក់ជាតិ អាចលុបចោលកម្ចីដែល

បានជំពាក់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងកាលៈទេសៈបែបនេះ រដ្ឋបាលថ្នាក់ក្រោមជាតិទទួលស្គាល់ការកើនឡើងនៃទ្រព្យសកម្មសុទ្ធ ព្រោះបំណុលដែលខ្លួនបានទទួលស្គាល់ពីមុន ត្រូវបានផុតរលត់។

៨៥. ស្ថាប័នទទួលស្គាល់ចំណូលពាក់ព័ន្ធនឹងការអនុគ្រោះបំណុល នៅពេលបំណុលចាស់លែងបំពេញតាមនិយមន័យនៃបំណុល ឬ បំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាបំណុលតទៅទៀត ក្នុងករណីដែលការអនុគ្រោះបំណុលមិនបំពេញតាមនិយមន័យនៃវិភាគទានពីម្ចាស់។

៨៦. នៅពេលស្ថាប័នគ្រប់គ្រង អនុគ្រោះបំណុលដែលបានជំពាក់ដោយស្ថាប័នក្រោមការគ្រប់គ្រងទាំងស្រុង ឬ ធ្វើការសន្មតបំណុលរបស់ខ្លួន, ប្រតិបត្តិការនោះអាចជាវិភាគទានពីម្ចាស់ ដូចបានពិពណ៌នាក្នុងកថាខណ្ឌ ៣៧-៣៨។

៨៧. ចំណូលដែលកើតឡើងពីការអនុគ្រោះបំណុល ត្រូវបានវាស់វែងតាមតម្លៃយោងនៃបំណុលដែលត្រូវបានអនុគ្រោះ។

**ការផាកពិន័យ**

៨៨. ការផាកពិន័យ គឺជាអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលបានទទួល ឬ ត្រូវទទួលដោយស្ថាប័នសាធារណៈ ពីបុគ្គល ឬ ស្ថាប័នផ្សេងទៀត ដូចបានកំណត់ដោយតុលាការ ឬ ស្ថាប័នអនុវត្តច្បាប់ដទៃផ្សេងទៀត ជាលទ្ធផលនៃការបំពានរបស់បុគ្គល ឬ ស្ថាប័នដទៃទៀតទៅលើលក្ខខណ្ឌចាំបាច់នៃច្បាប់ ឬ បទប្បញ្ញត្តិ។ ក្នុងយុត្តាធិការមួយចំនួន មន្ត្រីអនុវត្តច្បាប់ អាចកំណត់ការផាកពិន័យចំពោះបុគ្គលដែលត្រូវបានចាត់ទុកថាបានបំពានច្បាប់។ ក្នុងករណីទាំងនេះ ជាធម្មតា បុគ្គលម្នាក់ៗនឹងមានជម្រើសក្នុងការបង់ប្រាក់ផាកពិន័យ ឬ ទៅតុលាការដើម្បីការពាររឿងក្តី។ នៅពេលដែលចុងចោទឈានដល់កិច្ចព្រមព្រៀងជាមួយព្រះរាជអាជ្ញា ដែលរួមបញ្ចូលទាំងការបង់ប្រាក់ទោសទណ្ឌ ជំនួសឱ្យការកាត់ទោសនៅក្នុងតុលាការ, ការទូទាត់ត្រូវបានទទួលស្គាល់ជាការផាកពិន័យ។

៨៩. ការផាកពិន័យ ជាធម្មតាតម្រូវឱ្យស្ថាប័នធ្វើការផ្ទេរចំនួនសាច់ប្រាក់ថេរទៅកាន់រាជរដ្ឋាភិបាល ហើយមិនកំណត់កាតព្វកិច្ចណាមួយលើរាជរដ្ឋាភិបាល ដែលអាចត្រូវបានទទួលស្គាល់ជាបំណុលនោះទេ។ ដូចនេះការផាកពិន័យ ត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលការផាកពិន័យដែលត្រូវទទួល បំពេញតាមនិយមន័យនៃទ្រព្យសកម្ម និងបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្មដូចបានកំណត់ក្នុងកថាខណ្ឌ ៣១។ ដូចបានកត់សម្គាល់ក្នុងកថាខណ្ឌ ១២, នៅពេលស្ថាប័នប្រមូលការផាកពិន័យក្នុងនាមជាភ្នាក់ងារ, ការផាកពិន័យ នឹងមិនមែនជាចំណូលរបស់ស្ថាប័នប្រមូលចំណូលទេ។ ទ្រព្យសកម្មដែលកើតឡើងពីការផាកពិន័យ ត្រូវបានវាស់វែងតាមការប៉ាន់ស្មានដ៏គួរឱ្យជឿជាក់នៃលំហូរចូលនៃធនធានទៅកាន់ស្ថាប័ន។

**អច្ច័យទាន**

៩០. អច្ច័យទាន គឺជាការផ្ទេរដែលត្រូវបានធ្វើឡើងតាមបទប្បញ្ញត្តិនៃឆន្ទៈរបស់អ្នកដែលបានទទួលមរណភាព។ ព្រឹត្តិការណ៍នាពេលអតីត ដែលបង្កើតឱ្យមានការគ្រប់គ្រងលើធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ

សក្តានុពលសេវានាពេលអនាគតសម្រាប់អច្ច័យទាន កើតឡើងនៅពេលស្ថាប័នមានសិទ្ធិទាមទារដែលអាចចាប់បង្ខំ ឧទាហរណ៍ ទៅលើមរណភាពរបស់ម្ចាស់មរតក ឬ ការផ្តល់សុពលកម្ម ដោយអាស្រ័យលើច្បាប់របស់យុត្តាធិការ។

៩១. អច្ច័យទានដែលបំពេញតាមនិយមន័យនៃទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម និងចំណូលនៅពេលវាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត នឹងហូរចូលស្ថាប័ន ហើយតម្លៃសមស្របនៃទ្រព្យសកម្ម អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។ ការកំណត់អំពីភាពអាចនឹងកើតមានឡើងនៃលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត អាចនឹងមានភាពមិនជាក់លាក់ ប្រសិនបើការិយបរិច្ឆេទណាមួយកន្លងផុតទៅរវាងមរណភាពរបស់ម្ចាស់មរតក និងស្ថាប័នដែលទទួលទ្រព្យសកម្មណាមួយ។ ស្ថាប័ននឹងចាំបាច់ត្រូវកំណត់ថាតើទ្រព្យសម្បត្តិរបស់បុគ្គលដែលទទួលមរណភាព មានភាពគ្រប់គ្រាន់ដើម្បីបំពេញតាមសិទ្ធិទាមទារទាំងអស់ និងបំពេញបានជាអច្ច័យទានទាំងអស់ដែរឬទេ។ ប្រសិនបើឆន្ទៈត្រូវបានជំទាស់ វាក៏នឹងជះឥទ្ធិពលដល់ភាពដែលអាចកើតមានឡើងនៃទ្រព្យសកម្មដែលហូរចូលទៅកាន់ស្ថាប័នផងដែរ។

៩២. តម្លៃសមស្របនៃទ្រព្យសកម្មដែលបានធ្វើអច្ច័យទាន ត្រូវបានកំណត់នៅក្នុងមធ្យោបាយដូចគ្នានឹងកាដូ និងការបរិច្ចាគ ដូចបានពិពណ៌នានៅក្នុងកថាខណ្ឌ ៩៧។ នៅក្នុងយុត្តាធិការដែលទ្រព្យសម្បត្តិរបស់អ្នកដែលបានទទួលមរណភាព ត្រូវជាប់ពន្ធ, រដ្ឋបាលសារពើពន្ធប្រហែលជាបានកំណត់រួចហើយអំពីតម្លៃសមស្របនៃទ្រព្យសកម្មដែលបានធ្វើអច្ច័យទានឱ្យទៅស្ថាប័ន ហើយចំនួនទឹកប្រាក់នេះអាចមានសម្រាប់ស្ថាប័ន។ អច្ច័យទានត្រូវបានវាស់វែងតាមតម្លៃសមស្របនៃធនធានដែលបានទទួល ឬ ត្រូវទទួល។

### កាដូ និងការបរិច្ចាគ រួមបញ្ចូលទាំងទំនិញដែលបានពីការបរិច្ចាគ

៩៣. កាដូ និងការបរិច្ចាគ គឺជាការផ្ទេរទ្រព្យសកម្មដោយស្ម័គ្រចិត្ត ដែលរួមមាន សាច់ប្រាក់ ឬ ទ្រព្យសកម្មជារូបិយវត្ថុ, ទំនិញដែលបានពីការបរិច្ចាគ និងសេវាដែលបានពីការបរិច្ចាគផ្សេងទៀត ដែលស្ថាប័នធ្វើឡើងទៅកាន់ស្ថាប័នដទៃ ដែលជាធម្មតាមិនគិតពីលក្ខន្តិកៈ។ អ្នកផ្ទេរ អាចជាស្ថាប័ន ឬបុគ្គល។ សម្រាប់កាដូ និងការបរិច្ចាគសាច់ប្រាក់ ឬ ទ្រព្យសកម្មជារូបិយវត្ថុផ្សេងទៀត និងទំនិញដែលបានពីការបរិច្ចាគ, ព្រឹត្តិការណ៍នាពេលអតីតដែលបង្កើតឱ្យមានការគ្រប់គ្រងលើធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្តានុពលសេវានាពេលអនាគត ជាធម្មតាគឺជាចំណូលដែលទទួលបានពីកាដូ ឬ ការបរិច្ចាគ។ ការទទួលស្គាល់កាដូ ឬ ការបរិច្ចាគសេវាដែលបានពីការបរិច្ចាគ ត្រូវបានបង្ហាញនៅក្នុងកថាខណ្ឌ ៩៨-១០៣ ខាងក្រោម។

៩៤. ទំនិញដែលបានពីការបរិច្ចាគ គឺជាទ្រព្យសកម្មរូបីដែលត្រូវបានផ្ទេរទៅកាន់ស្ថាប័ន ជាប្រតិបត្តិការមិនដោះដូរ ដោយមិនគិតប្រាក់ ប៉ុន្តែអាចស្ថិតក្រោមលក្ខន្តិកៈ។ ជំនួយពីខាងក្រៅដែលបានផ្តល់ដោយអង្គការអភិវឌ្ឍន៍ទ្វេភាគី ឬ ពហុភាគី តែងតែរួមបញ្ចូលនូវសមាសធាតុមួយនៃទំនិញដែលបានពីការបរិច្ចាគ។

៩៥. កាដូ និងការបរិច្ចាគ (ជាជាងសេវាដែលបានពីការបរិច្ចាគ) ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម និងចំណូល នៅពេលវាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេល

អនាគត នឹងហូរចូលស្ថាប័ន ហើយតម្លៃសមស្របនៃទ្រព្យសកម្ម អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។ ជាមួយនឹងកាដូ និងការបរិច្ចាគ, ការផ្តល់កាដូ ឬ ការបរិច្ចាគ និងការផ្ទេរសិទ្ធិស្របច្បាប់ ជាទូទៅកើតឡើងក្នុងពេលដំណាលគ្នា។ ក្នុងកាលៈទេសៈបែបនេះ គ្មានការសង្ស័យទេដែលអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ហូរចូលទៅកាន់ស្ថាប័ន។

៩៦. ទំនិញដែលបានពីការបរិច្ចាគ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម នៅពេលទំនិញត្រូវបានទទួល ឬ មានកិច្ចសម្រុះសម្រួលដែលចងកាតព្វកិច្ចអនុវត្តក្នុងការទទួលទំនិញ។ ប្រសិនបើទំនិញដែលបានពីការបរិច្ចាគត្រូវបានទទួលដោយមិនមានលក្ខខណ្ឌភ្ជាប់មកជាមួយ ចំណូលត្រូវបានទទួលស្គាល់ភ្លាមៗ។ ប្រសិនបើលក្ខខណ្ឌត្រូវបានភ្ជាប់មកជាមួយ, បំណុលត្រូវបានទទួលស្គាល់ ដែលត្រូវបានកាត់បន្ថយ ហើយចំណូលត្រូវបានទទួលស្គាល់ នៅពេលលក្ខខណ្ឌត្រូវបានបំពេញ។

៩៧. នៅពេលទទួលស្គាល់លើកដំបូង, កាដូ និងការបរិច្ចាគ ដែលរួមបញ្ចូលទាំងទំនិញដែលបានពីការបរិច្ចាគត្រូវបានវាស់វែងតាមតម្លៃសមស្រប នាកាលបរិច្ឆេទនៃការទិញ ដែលត្រូវបានបញ្ជាក់ដោយយោងទៅលើទីផ្សារសកម្ម ឬតាមរយៈការវាយតម្លៃ។ ការវាយតម្លៃទ្រព្យសកម្ម ជាធម្មតាត្រូវបានធ្វើឡើងដោយសមាជិកនៃក្រុមអ្នកជំនាញវាយតម្លៃដែលមានការទទួលស្គាល់ និងមានគុណវុឌ្ឍិវិជ្ជាជីវៈពាក់ព័ន្ធ។ សម្រាប់ទ្រព្យសកម្មជាច្រើន តម្លៃសមស្របនឹងត្រូវបានបញ្ជាក់ដោយយោងទៅលើតម្លៃដែលបានដកស្រង់ក្នុងទីផ្សារសកម្ម និងទីផ្សារដែលមានសន្ទនីយភាព។ ឧទាហរណ៍ តម្លៃទីផ្សារបច្ចុប្បន្ន ជាធម្មតាអាចទទួលបានសម្រាប់ដីធ្លី, អគារដែលមិនមានលក្ខណៈពិសេស, យានយន្ត ព្រមទាំងរោងចក្រ និងបរិក្ខារជាច្រើនប្រភេទទៀត។

### សេវាដែលបានពីការបរិច្ចាគ

៩៨. **ស្ថាប័នអាច ប៉ុន្តែមិនតម្រូវឱ្យ ទទួលស្គាល់សេវាដែលបានពីការបរិច្ចាគ ជាចំណូល និងជាទ្រព្យសកម្មទេ។**

៩៩. សេវាដែលបានពីការបរិច្ចាគ ជាសេវាដែលបានផ្តល់ដោយបុគ្គលទៅកាន់ស្ថាប័នសាធារណៈ ក្នុងប្រតិបត្តិការមិនដោះដូរ។ សេវាទាំងនេះបំពេញតាមនិយមន័យនៃទ្រព្យសកម្ម ពីព្រោះស្ថាប័នគ្រប់គ្រងធនធានដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ត្រូវបានរំពឹងថានឹងហូរចូលស្ថាប័នចេញពីធនធានទាំងនោះ។ ប៉ុន្តែ ទ្រព្យសកម្មទាំងនេះត្រូវបានប្រើប្រាស់ភ្លាមៗ ហើយប្រតិបត្តិការដែលមានតម្លៃស្មើ ក៏ត្រូវបានទទួលស្គាល់ផងដែរ ដើម្បីឆ្លុះបញ្ចាំងពីការប្រើប្រាស់សេវាដែលបានពីការបរិច្ចាគទាំងនេះ។ ឧទាហរណ៍ សាលារៀនរដ្ឋមួយដែលទទួលបានសេវាស្ម័គ្រចិត្តពីជំនួយការគ្រូ ដែលតម្លៃសមស្របនៃសេវានោះអាចត្រូវបានវាស់វែងដោយជឿទុកចិត្ត, អាចទទួលស្គាល់នូវការកើនឡើងនៃទ្រព្យសកម្មនិងចំណូល ហើយទទួលស្គាល់នូវការថយចុះនៃទ្រព្យសកម្មនិងចំណាយ។ ក្នុងករណីជាច្រើន ស្ថាប័ននឹងទទួលស្គាល់ចំណាយសម្រាប់ការប្រើប្រាស់សេវាដែលបានពីការបរិច្ចាគ។ ប៉ុន្តែ សេវាដែលបានពីការបរិច្ចាគ ក៏អាចត្រូវបានប្រើប្រាស់ដើម្បីសាងសង់ទ្រព្យសកម្ម ក្នុងករណីដែលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ពាក់ព័ន្ធនឹងសេវាដែលបានពីការបរិច្ចាគ ត្រូវបានរួមបញ្ចូលទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មដែលកំពុងសាងសង់។

១០០. ស្ថាប័នសាធារណៈ អាចជាអ្នកទទួលផលពីសេវាដែលបានពីការបរិច្ចាគ ក្រោមគោលការណ៍ស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្ត ដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ។ ឧទាហរណ៍÷

(ក) ជំនួយបច្ចេកទេសពីរាជរដ្ឋាភិបាលដទៃ ឬ អង្គការអន្តរជាតិ

(ខ) បុគ្គលដែលត្រូវបានផ្តន្ទាទោសពីបទល្មើស អាចនឹងតម្រូវឱ្យបំពេញសេវាសហគមន៍សម្រាប់ស្ថាប័នសាធារណៈ

(គ) មន្ទីរពេទ្យរដ្ឋ អាចទទួលបានសេវាពីអ្នកស្ម័គ្រចិត្ត

(ឃ) សាលារៀនរដ្ឋ អាចទទួលបានសេវាស្ម័គ្រចិត្តពីអាណាព្យាបាលសិស្ស ជាជំនួយការគ្រូ ឬ ជាសមាជិកក្រុមប្រឹក្សាភិបាល និង

(ង) រដ្ឋបាលថ្នាក់ក្រោមជាតិ អាចទទួលបានសេវាពីអ្នកពន្លត់អគ្គិភ័យស្ម័គ្រចិត្ត។

១០១. សេវាដែលបានពីការបរិច្ចាគមួយចំនួន មិនបានបំពេញតាមនិយមន័យនៃទ្រព្យសកម្មនោះទេ ពីព្រោះស្ថាប័នមិនមានការគ្រប់គ្រងពេញលេញលើសេវាដែលបានផ្តល់។ ក្នុងកាលៈទេសៈផ្សេងទៀត ស្ថាប័នអាចមានការគ្រប់គ្រងលើសេវាដែលបានពីការបរិច្ចាគ ប៉ុន្តែប្រហែលជាមិនអាចវាស់វែងសេវាដែលបានពីការបរិច្ចាគទាំងនោះដោយជឿទុកចិត្តបានទេ ដូចនេះ សេវាដែលបានពីការបរិច្ចាគទាំងនោះមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្មឡើយ។ ទោះបីជាយ៉ាងណា ស្ថាប័នអាចធ្វើការវាស់វែងតម្លៃសមស្របនៃសេវាដែលបានពីការបរិច្ចាគជាក់លាក់ ដូចជា សេវាដែលបានពីការបរិច្ចាគបែបវិជ្ជាជីវៈ ឬ សេវាដែលបានពីការបរិច្ចាគផ្សេងទៀតដែលអាចរកបាននៅក្នុងទីផ្សារជាតិ ឬ ទីផ្សារអន្តរជាតិ។ នៅពេលកំណត់អំពីតម្លៃសមស្របនៃប្រភេទសេវាដែលបានពីការបរិច្ចាគដូចបានពិពណ៌នានៅក្នុងកថាខណ្ឌ ១០០, ស្ថាប័នអាចសន្និដ្ឋានបានថា តម្លៃសេវាមិនមានភាពជាសារវន្តទេ។ នៅក្នុងករណីជាច្រើន សេវាដែលបានពីការបរិច្ចាគ ត្រូវបានផ្តល់ដោយបុគ្គលដែលមិនទទួលបាន ឬ ទទួលបានការបណ្តុះបណ្តាលតិចតួច ហើយមានភាពខុសគ្នាច្រើនពីសេវាដែលស្ថាប័នអាចនឹងទិញ ប្រសិនបើសេវាដែលបានពីការបរិច្ចាគ មិនអាចរកបាន។

១០២. ដោយមានភាពមិនច្បាស់លាស់ច្រើនពាក់ព័ន្ធនឹងសេវាដែលបានពីការបរិច្ចាគ ដែលរួមបញ្ចូលទាំងសមត្ថភាពក្នុងការគ្រប់គ្រងសេវា និងការវាស់វែងតម្លៃសមស្របនៃសេវា, ស្តង់ដានេះមិនតម្រូវឱ្យមានការទទួលស្គាល់សេវាដែលបានពីការបរិច្ចាគនោះទេ។ ទោះបីជាយ៉ាងណា កថាខណ្ឌ ១០៨ លើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីចរិតលក្ខណៈ និងប្រភេទនៃសេវាដែលបានពីការបរិច្ចាគដែលបានទទួលក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។ ដូចគ្នានឹងការលាតត្រដាងទាំងអស់ដែរ ការលាតត្រដាងដែលពាក់ព័ន្ធនឹងសេវាដែលបានពីការបរិច្ចាគ ត្រូវបានធ្វើឡើងតែនៅពេលដែលសេវាដែលបានពីការបរិច្ចាគទាំងនោះមានភាពជាសារវន្តប៉ុណ្ណោះ។ សម្រាប់ស្ថាប័នសាធារណៈមួយចំនួន សេវាដែលបានផ្តល់ដោយអ្នកស្ម័គ្រចិត្ត មិនមានភាពជាសារវន្តជាចំនួនទឹកប្រាក់ទេ ប៉ុន្តែអាចមានភាពជាសារវន្តជាចរិតលក្ខណៈ។

១០៣. ក្នុងការរៀបចំគោលនយោបាយគណនេយ្យ សម្រាប់ដោះស្រាយថ្នាក់នៃសេវាដែលបានពីការបរិច្ចាគ, កត្តាជាច្រើនអាចនឹងត្រូវពិចារណា រាប់បញ្ចូលទាំងផលប៉ះពាល់នៃសេវាដែលបានពីការបរិច្ចាគទាំងនោះ មកលើស្ថានភាពហិរញ្ញវត្ថុ, លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ស្ថាប័ន។ វិសាលភាពដែលស្ថាប័ន ពឹងផ្អែកលើថ្នាក់នៃសេវាដែលបានពីការបរិច្ចាគ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន អាចមាន ឥទ្ធិពលដល់គោលនយោបាយគណនេយ្យដែលស្ថាប័នបង្កើត ពាក់ព័ន្ធនឹងការទទួលស្គាល់ទ្រព្យសកម្ម។ ឧទាហរណ៍ ស្ថាប័នដែលពឹងផ្អែកលើថ្នាក់នៃសេវាដែលបានពីការបរិច្ចាគដើម្បីសម្រេចបាននូវគោលបំណង របស់ខ្លួន អាចនឹងទទួលស្គាល់សេវាដែលបានពីការបរិច្ចាគទាំងនោះ ដែលបំពេញតាមនិយមន័យនៃទ្រព្យ-សកម្ម និងបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់។ ក្នុងការកំណត់ថាតើត្រូវទទួលស្គាល់ថ្នាក់ នៃសេវាដែលបានពីការបរិច្ចាគ ឬក៏អត់, ការអនុវត្តរបស់ស្ថាប័នប្រហាក់ប្រហែលគ្នាដែលមានប្រតិបត្តិការ នៅក្នុងបរិយាកាសស្រដៀងគ្នា ក៏គួរត្រូវបានពិចារណាផងដែរ។

## វត្ថុបញ្ចាំ

១០៤. វត្ថុបញ្ចាំ គឺជាការសន្យាដែលមិនអាចចាប់បង្ខំឱ្យអនុវត្ត ក្នុងការផ្ទេរទ្រព្យសកម្មទៅកាន់ស្ថាប័នដែលជាអ្នក ទទួលផល។ វត្ថុបញ្ចាំមិនបំពេញតាមនិយមន័យនៃទ្រព្យសកម្មទេ ពីព្រោះស្ថាប័នដែលជាអ្នកទទួលផល មិនអាចគ្រប់គ្រងសិទ្ធិរបស់អ្នកផ្ទេរក្នុងការទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេល អនាគតដែលមាននៅក្នុងធាតុដែលបានបញ្ចាំ។ ស្ថាប័នមិនទទួលស្គាល់ធាតុដែលបានបញ្ចាំជាទ្រព្យសកម្ម ឬ ចំណូលនោះទេ។ ប្រសិនបើធាតុដែលបានបញ្ចាំ ត្រូវបានផ្ទេរនាពេលបន្តបន្ទាប់ទៅកាន់ស្ថាប័នដែល ជាអ្នកទទួលផល ធាតុដែលបានបញ្ចាំនោះត្រូវបានទទួលស្គាល់ជាកាដូ ឬ ការបរិច្ចាគ ដោយអនុលោម តាមកថាខណ្ឌ ៩៣-៩៧ ខាងលើ។ វត្ថុបញ្ចាំ អាចធានាការលាតត្រដាងជាទ្រព្យសកម្មយថាហេតុ ក្រោម លក្ខខណ្ឌចាំបាច់នៃស្តង់ដា CPSAS 19។

## ចំណូលពីការផ្ទេរដែលបានទទួលមុន

១០៥. នៅពេលស្ថាប័នទទួលបានធនធាន មុនពេលដែលកិច្ចសម្រុះសម្រួលនៃការផ្ទេរ បានចងកាតព្វកិច្ចអនុវត្ត, ធនធានត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម នៅពេលធនធានបានបំពេញតាមនិយមន័យនៃទ្រព្យសកម្ម និងបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្ម។ ស្ថាប័នក៏នឹងទទួលស្គាល់បំណុល នៃចំណូលដែលបានទទួលមុនផងដែរ ប្រសិនបើកិច្ចសម្រុះសម្រួលនៃការផ្ទេរ មិនទាន់បានចងកាតព្វកិច្ច អនុវត្តនៅឡើយ។ ចំណូលដែលបានទទួលមុនពាក់ព័ន្ធនឹងការផ្ទេរ មិនមានភាពខុសគ្នាច្រើនពីចំណូល ដែលទទួលបានមុនដទៃទៀតនោះទេ ដូចនេះ បំណុលត្រូវបានទទួលស្គាល់រហូតដល់ព្រឹត្តិការណ៍ដែល ធ្វើឱ្យកិច្ចសម្រុះសម្រួលនៃការផ្ទេរចងជាកាតព្វកិច្ចអនុវត្ត បានកើតឡើង ហើយគ្រប់លក្ខខណ្ឌផ្សេងទៀត ក្រោមកិច្ចព្រមព្រៀង ត្រូវបានបំពេញ។ នៅពេលព្រឹត្តិការណ៍នោះកើតឡើង ហើយគ្រប់លក្ខខណ្ឌផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងត្រូវបានបំពេញ, បំណុលត្រូវបានទូទាត់រួច ហើយចំណូលត្រូវបានទទួលស្គាល់។

## កម្ចីសម្បទាន

១០៥ក. កម្ចីសម្បទាន គឺជាកម្ចីដែលស្ថាប័នបានទទួលក្នុងលក្ខខណ្ឌក្រោមទីផ្សារ។ ចំណែកនៃកម្ចីដែលត្រូវទូទាត់សង រួមជាមួយនឹងការទូទាត់ការប្រាក់ណាមួយ គឺជាប្រតិបត្តិការដោះដូរ ហើយត្រូវបានទទួលស្គាល់ដោយអនុលោមតាមស្តង់ដា CPSAS 41។ ស្ថាប័នគួរពិចារណាថាតើភាពខុសគ្នាណាមួយរវាងតម្លៃប្រតិបត្តិការ (ចំណូលពីកម្ចី) និងតម្លៃសមស្របនៃកម្ចីនាការទទួលស្គាល់លើកដំបូង (សូមមើលស្តង់ដា CPSAS 41) គឺជាចំណូលមិនដោះដូរ ដែលគួរត្រូវបានទទួលស្គាល់ដោយអនុលោមតាមស្តង់ដានេះ។

១០៥ខ. នៅពេលស្ថាប័នកំណត់ថា ភាពខុសគ្នារវាងតម្លៃប្រតិបត្តិការ (ចំណូលពីកម្ចី) និងតម្លៃសមស្របនៃកម្ចីនាការទទួលស្គាល់លើកដំបូង គឺជាចំណូលមិនដោះដូរ, ស្ថាប័នទទួលស្គាល់ភាពខុសគ្នានោះជាចំណូលលើកលែងតែប្រសិនបើកាតព្វកិច្ចបច្ចុប្បន្នកើតឡើង ឧទាហរណ៍ នៅពេលលក្ខខណ្ឌជាក់លាក់ដែលត្រូវបានកំណត់ដោយអ្នកទទួលផល ទៅលើទ្រព្យសកម្មដែលបានផ្ទេរ បង្កើតឱ្យមានកាតព្វកិច្ចបច្ចុប្បន្ន។ នៅពេលកាតព្វកិច្ចបច្ចុប្បន្នកើតឡើង កាតព្វកិច្ចបច្ចុប្បន្នត្រូវបានទទួលស្គាល់ជាបំណុល។ នៅពេលស្ថាប័នបំពេញតាមកាតព្វកិច្ចបច្ចុប្បន្ន បំណុលត្រូវបានកាត់បន្ថយ ហើយចំនួនទឹកប្រាក់នៃចំណូលដែលស្មើគ្នាត្រូវបានទទួលស្គាល់។

## ការលាតត្រដាង

**១០៦. ស្ថាប័នត្រូវលាតត្រដាងនៅលើផ្ទៃនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ឬ នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ អំពី÷**

**(ក) ចំនួនទឹកប្រាក់នៃចំណូលដែលទទួលបានពីប្រតិបត្តិការមិនដោះដូរដែលត្រូវបានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទ ទៅតាមចំណាត់ថ្នាក់សំខាន់ៗដែលបង្ហាញដាច់ដោយឡែកអំពី÷**

**(១) ពន្ធ ដែលបង្ហាញដាច់ដោយឡែកអំពីចំណាត់ថ្នាក់សំខាន់ៗនៃពន្ធ និង**

**(២) ការផ្ទេរ ដែលបង្ហាញដាច់ដោយឡែកអំពីចំណាត់ថ្នាក់សំខាន់ៗនៃចំណូលពីការផ្ទេរ។**

**(ខ) ចំនួនទឹកប្រាក់ដែលត្រូវទទួលដែលត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងចំណូលមិនដោះដូរ**

**(គ) ចំនួនទឹកប្រាក់នៃបំណុលដែលត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងទ្រព្យសកម្មដែលបានផ្ទេរដែលស្ថិតក្រោមលក្ខខណ្ឌ**

**(គ.ក) ចំនួនទឹកប្រាក់នៃបំណុលដែលត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងកម្ចីសម្បទាន ដែលស្ថិតក្រោមលក្ខខណ្ឌលើទ្រព្យសកម្មដែលបានផ្ទេរ**

**(ឃ) ចំនួនទឹកប្រាក់នៃទ្រព្យសកម្មដែលត្រូវបានទទួលស្គាល់ ដែលស្ថិតក្រោមការរឹតត្បិត និងចរិតលក្ខណៈនៃការរឹតត្បិតទាំងនោះ**

**(ង) ការកើតឡើង និងចំនួនទឹកប្រាក់នៃចំណូលដែលបានទទួលមុនណាមួយ ពាក់ព័ន្ធនឹងប្រតិបត្តិការមិនដោះដូរ និង**

**(ច) ចំនួនទឹកប្រាក់នៃបំណុលណាមួយដែលត្រូវបានអនុគ្រោះ។**

**១០៧. ស្ថាប័នត្រូវលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ អំពី÷**

**(ក) គោលនយោបាយគណនេយ្យ ដែលត្រូវបានប្រើសម្រាប់ការទទួលស្គាល់ចំណូលពីប្រតិបត្តិការមិនដោះដូរ**

**(ខ) មូលដ្ឋានដែលតម្លៃសមស្របនៃធនធានដែលបានហូរចូលត្រូវបានវាស់វែង សម្រាប់ចំណាត់ថ្នាក់សំខាន់ៗនៃចំណូលពីប្រតិបត្តិការមិនដោះដូរ**

**(គ) ព័ត៌មានអំពីចរិតលក្ខណៈនៃពន្ធ សម្រាប់ចំណាត់ថ្នាក់សំខាន់ៗនៃចំណូលសារពើពន្ធដែលស្ថាប័នមិនអាចវាស់វែងបានដោយជឿទុកចិត្ត នៅក្នុងអំឡុងការិយបរិច្ឆេទដែលព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង និង**

**(ឃ) ចរិតលក្ខណៈ និងប្រភេទចំណាត់ថ្នាក់សំខាន់ៗនៃអច្ច័យទាន កាដូ និងការបរិច្ចាគ ដែលបង្ហាញដាច់ដោយឡែកអំពីចំណាត់ថ្នាក់សំខាន់ៗនៃទំនិញដែលបានពីការបរិច្ចាគដែលបានទទួល។**

១០៨. ស្ថាប័នត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងអំពីចរិតលក្ខណៈនិងប្រភេទចំណាត់ថ្នាក់សំខាន់ៗនៃសេវាដែលបានពីការបរិច្ចាគដែលបានទទួល រួមបញ្ចូលទាំងសេវាដែលបានពីការបរិច្ចាគដែលមិនបានទទួលស្គាល់។ វិសាលភាពដែលស្ថាប័នពឹងផ្អែកលើចំណាត់ថ្នាក់នៃសេវាដែលបានពីការបរិច្ចាគ នឹងកំណត់អំពីការលាតត្រដាងដែលស្ថាប័នត្រូវធ្វើ ពាក់ព័ន្ធនឹងចំណាត់ថ្នាក់នោះ។

១០៩. ការលាតត្រដាងដែលបានតម្រូវដោយកថាខណ្ឌ ១០៦ និង ១០៧ ជួយឱ្យស្ថាប័នរាយការណ៍បំពេញតាមគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ ដូចបានកំណត់នៅក្នុងស្តង់ដា CPSAS 1 ដែលស្ថាប័នត្រូវផ្តល់ព័ត៌មានដែលមានសារៈសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងដើម្បីបង្ហាញពីគណនេយ្យភាពរបស់ស្ថាប័នចំពោះធនធានដែលបានផ្តល់ឱ្យស្ថាប័ន។

១១០. ការលាតត្រដាងអំពីថ្នាក់សំខាន់ៗនៃចំណូល ជួយឱ្យអ្នកប្រើប្រាស់អាចធ្វើការវិនិច្ឆ័យបានគ្រប់ជ្រុងជ្រោយអំពីការបើកចំហរបស់ស្ថាប័នទៅកាន់ប្រភពចំណូលជាក់លាក់។

១១១. លក្ខខណ្ឌនិងការរឹតត្បិត ដាក់កម្រិតលើការប្រើប្រាស់ទ្រព្យសកម្ម ដែលជះឥទ្ធិពលដល់កិច្ចប្រតិបត្តិការរបស់ស្ថាប័ន។ ការលាតត្រដាងអំពី (ក) ចំនួនទឹកប្រាក់នៃបំណុលដែលត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងលក្ខខណ្ឌ និង (ខ) ចំនួនទឹកប្រាក់នៃទ្រព្យសកម្មដែលស្ថិតក្រោមការរឹតត្បិត ជួយដល់អ្នកប្រើប្រាស់ក្នុងការវិនិច្ឆ័យអំពីសមត្ថភាពរបស់ស្ថាប័នក្នុងការប្រើប្រាស់ទ្រព្យសកម្មតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ស្ថាប័នត្រូវបានលើកទឹកចិត្តឱ្យញែកព័ត៌មានដែលបានតម្រូវឱ្យលាតត្រដាងតាមកថាខណ្ឌ ១០៦ (គ) ទៅតាមថ្នាក់។

១១២. កថាខណ្ឌ ១០៦ (ង) តម្រូវឱ្យស្ថាប័នលាតត្រដាងអំពីការកើតមានឡើងនៃចំណូលដែលបានទទួលមុនពាក់ព័ន្ធនឹងប្រតិបត្តិការមិនដោះដូរ។ បំណុលទាំងនេះនាំមកជាមួយនូវហានិភ័យដែលស្ថាប័ននឹងចាំបាច់ត្រូវលះបង់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត ប្រសិនបើព្រឹត្តិការណ៍ជាប់ពន្ធមិនបានកើតឡើង ឬ កិច្ចសម្រុះសម្រួលនៃការផ្ទេរ មិនចងជាកាតព្វកិច្ចអនុវត្ត។ ការលាតត្រដាងអំពី

ចំណូលដែលបានទទួលមុនទាំងនេះ ជួយឱ្យអ្នកប្រើប្រាស់អាចធ្វើការវិនិច្ឆ័យអំពីចំណូលនាពេលអនាគត និងស្ថានភាពទ្រព្យសកម្មសុទ្ធរបស់ស្ថាប័ន។

១១៣. ដូចបានកត់សម្គាល់នៅក្នុងកថាខណ្ឌ ៦៨, ក្នុងករណីជាច្រើន ស្ថាប័ននឹងអាចវាស់វែងដោយជឿទុកចិត្តនូវទ្រព្យសកម្មនិងចំណូលដែលកើតឡើងពីប្រតិបត្តិការសារពើពន្ធ ដោយប្រើប្រាស់ ឧទាហរណ៍ គំរូស្ថិតិ។ ទោះបីជាយ៉ាងណា អាចមានកាលៈទេសៈលើកលែងដែលស្ថាប័នមិនអាចវាស់វែងទ្រព្យសកម្មនិងចំណូលដែលកើតឡើង ដោយជឿទុកចិត្ត រហូតដល់ការិយបរិច្ឆេទរាយការណ៍មួយ ឬច្រើន បានកន្លងផុត ចាប់តាំងពីព្រឹត្តិការណ៍ជាប់ពន្ធបានកើតឡើង។ ក្នុងករណីទាំងនេះ ស្ថាប័នធ្វើការលាតត្រដាងអំពីចរិតលក្ខណៈនៃចំណាត់ថ្នាក់សំខាន់ៗនៃពន្ធដែលមិនអាចវាស់វែងបានដោយជឿទុកចិត្ត ហើយជាលទ្ធផលត្រូវបានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ដែលព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង។ ការលាតត្រដាងទាំងនេះ ជួយឱ្យអ្នកប្រើប្រាស់អាចធ្វើការវិនិច្ឆ័យអំពីចំណូលនាអនាគតនិងស្ថានភាពទ្រព្យសកម្មសុទ្ធរបស់ស្ថាប័ន។

១១៤. កថាខណ្ឌ ១០៧ (ឃ) តម្រូវឱ្យស្ថាប័នធ្វើការលាតត្រដាងអំពីចរិតលក្ខណៈ និងប្រភេទថ្នាក់សំខាន់ៗនៃកាដូ, ការបរិច្ចាគ និងអច្ច័យទានដែលខ្លួនបានទទួល។ លំហូរចូលនៃធនធានទាំងនេះត្រូវបានទទួលតាមឆន្ទានុសិទ្ធិរបស់អ្នកផ្ទេរ ដែលធ្វើឱ្យស្ថាប័នប្រឈមមុខនឹងហានិភ័យដែល នៅក្នុងការិយបរិច្ឆេទនាពេលអនាគត, ប្រភពធនធានទាំងនេះអាចនឹងមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ ការលាតត្រដាងទាំងនេះជួយឱ្យអ្នកប្រើប្រាស់អាចធ្វើការវិនិច្ឆ័យអំពីចំណូលនាពេលអនាគតនិងស្ថានភាពទ្រព្យសកម្មសុទ្ធរបស់ស្ថាប័ន។

១១៥. នៅពេលសេវាដែលបានពីការបរិច្ចាគ បំពេញតាមនិយមន័យនៃទ្រព្យសកម្មនិងបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ជាទ្រព្យសកម្ម, ស្ថាប័នអាចជ្រើសរើសក្នុងការទទួលស្គាល់និងវាស់វែងសេវាដែលបានពីការបរិច្ចាគទាំងនេះតាមតម្លៃសមស្រប។ កថាខណ្ឌ ១០៨ លើកទឹកចិត្តឱ្យស្ថាប័នធ្វើការលាតត្រដាងអំពីចរិតលក្ខណៈ និងប្រភេទសេវាដែលបានពីការបរិច្ចាគទាំងអស់ដែលបានទទួល មិនថាសេវាដែលបានពីការបរិច្ចាគទាំងនោះត្រូវបានទទួលស្គាល់ ឬមិនត្រូវបានទទួលស្គាល់ក៏ដោយ។ ការលាតត្រដាងទាំងនេះអាចជួយឱ្យអ្នកប្រើប្រាស់ធ្វើការវិនិច្ឆ័យបានគ្រប់ជ្រុងជ្រោយអំពី (ក) វិភាគទានដែលត្រូវបានបង្កើតឡើងដោយសេវាទាំងនេះ ដើម្បីសម្រេចបាននូវគោលបំណងរបស់ស្ថាប័នក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ និង (ខ) ការពឹងផ្អែករបស់ស្ថាប័នទៅលើសេវាទាំងនេះសម្រាប់ការសម្រេចបាននូវគោលបំណងរបស់ខ្លួននាពេលអនាគត។

# CPSAS 23 - REVENUE FROM NON-EXCHANGE TRANSACTIONS (TAXES AND TRANSFERS)

## Acknowledgment

Cambodian Public Sector Accounting Standard 23, is prepared based on the International Public Sector Accounting Standard 23, *Revenue from Non-Exchange Transactions (Taxes and Transfers)*, extract from the *Handbook of International Public Sector Accounting Pronouncement* of the International Public Sector Accounting Standards Board (IPSASB), published by the International Federation of Accountings (IFAC) in July 2020 and used with a permission of the International Federation of Accounting.

*Handbook of International Public Sector Accounting Pronouncement* ©2020 by the International Federation of Accountings (IFAC). All rights reserved.

Issued by:
Accounting and Auditing Regulator
Street 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh
Phone: +(855) 23 882 111
Email: info@acar.gov.kh
Website: www.acar.gov.kh

# CPSAS 23 — REVENUE FROM NON-EXCHANGE TRANSACTIONS (TAXES AND TRANSFERS)

## CONTENTS

Paragraph


Objective........1

Scope........2–6

Definitions........7–28

Non-Exchange Transactions........8–11

Revenue........12–13

Stipulations........14–16

Conditions on Transferred Assets........17–18

Restrictions on Transferred Assets........19

Substance over Form........20–25

Taxes........26–28

Analysis of the Initial Inflow of Resources from Non-Exchange Transactions........29

Recognition of Assets........30–43

Control of an Asset........32–33

Past Event........34

Probable Inflow of Resources........35

Contingent Assets........36

Contributions from Owners........37–38

Exchange and Non-Exchange Components of a Transaction........39–41

Measurement of Assets on Initial Recognition........42–43

Recognition of Revenue from Non-Exchange Transactions........44–47

Measurement of Revenue from Non-Exchange Transactions........48–49

Present Obligations Recognized as Liabilities........50–58

Present Obligation........51–54

Conditions on a Transferred Asset ....................................................................55–56

Measurement of Liabilities on Initial Recognition ....................................................57–58

Taxes ........................................................................................................................59–75

The Taxable Event ............................................................................................................65

Advance Receipts of Taxes ..............................................................................................66

Measurement of Assets Arising from Taxation Transactions ...................................67–70

Expenses Paid Through the Tax System and Tax Expenditures ................................71–75

Transfers ..............................................................................................................76–105B

Measurement of Transferred Assets ...............................................................................83

Debt Forgiveness and Assumption of Liabilities .......................................................84–87

Fines ..........................................................................................................................88–89

Bequests ....................................................................................................................90–92

Gifts and Donations, including Goods In-kind ..........................................................93–97

Services In-kind ........................................................................................................98–103

Pledges ..........................................................................................................................104

Advance Receipts of Transfers ......................................................................................105

Concessionary Loans .......................................................................................105A-105B

Disclosures ............................................................................................................106–115

## Objective

1. The objective of this Standard is to prescribe requirements for the financial reporting of revenue arising from non-exchange transactions, other than non-exchange transactions that give rise to a public sector combination. This Standard deals with issues that need to be considered in recognizing and measuring revenue from non-exchange transactions, including the identification of contributions from owners.

## Scope

2. **An entity that prepares and presents financial statements under the accrual basis of accounting shall apply this Standard in accounting for revenue from non-exchange transactions. This Standard does not apply to:**

   (a) **A public sector combination that is a non-exchange transaction; and**

   (b) **Contributions to social benefit schemes that are accounted for in accordance with paragraphs 26-31 of CPSAS 42, *Social Benefits* (the insurance approach).**

3. [Deleted]

4. [Deleted]

5. This Standard addresses revenue arising from non-exchange transactions. Revenue arising from exchange transactions is addressed in CPSAS 9, *Revenue from Exchange Transactions*. While revenues received by public sector entities arise from both exchange and non-exchange transactions, the majority of revenue of governments and other public sector entities is typically derived from non-exchange transactions, such as:

   (a) Taxes; and

   (b) Transfers (whether cash or noncash), including grants, debt forgiveness, fines, bequests, gifts, donations, goods and services in-kind, and the off-market portion of concessionary loans received.

6. Governments may reorganize the public sector, merging some public sector entities, and dividing other entities into two or more separate entities. A public sector combination occurs when two or more operations are brought together to form one reporting entity. These restructurings do not ordinarily involve one entity purchasing another operation or entity, but may result in a new or existing entity acquiring all the assets and liabilities of another operation or entity. Public sector combinations shall be accounted for in accordance with CPSAS 40, *Public Sector Combinations*.

## Definitions

7. **The following terms are used in this Standard with the meanings specified:**

   **<u>Conditions on transferred assets</u> are stipulations that specify that the future economic benefits or service potential embodied in the asset is required to be consumed by the recipient as specified or future economic benefits or service potential must be returned to the transferor.**

**<u>Control of an asset</u> arises when the entity can use or otherwise benefit from the asset in pursuit of its objectives, and can exclude or otherwise regulate the access of others to that benefit.**

**<u>Expenses paid through the tax system</u> are amounts that are available to beneficiaries regardless of whether or not they pay taxes.**

**<u>Fines</u> are economic benefits or service potential received or receivable by public sector entities, as determined by a court or other law enforcement body, as a consequence of the breach of laws or regulations.**

**<u>Restrictions on transferred assets</u> are stipulations that limit or direct the purposes for which a transferred asset may be used, but do not specify that future economic benefits or service potential is required to be returned to the transferor if not deployed as specified.**

**<u>Stipulations on transferred assets</u> are terms in laws or regulation, or a binding arrangement, imposed upon the use of a transferred asset by entities external to the reporting entity.**

**<u>Tax expenditures</u> are preferential provisions of the tax law that provide certain taxpayers with concessions that are not available to others.**

**<u>The taxable event</u> is the event that the government, legislature, or other authority has determined will be subject to taxation.**

**<u>Taxes</u> are economic benefits or service potential compulsorily paid or payable to public sector entities, in accordance with laws and/or regulations, established to provide revenue to the government. Taxes do not include fines or other penalties imposed for breaches of the law.**

**<u>Transfers</u> are inflows of future economic benefits or service potential from non-exchange transactions, other than taxes.**

**Terms defined in other CPSASs are used in this Standard with the same meaning as in those Standards, and are reproduced in the *Glossary of Defined Terms* published separately.**

**Non-Exchange Transactions**

8. In some transactions, it is clear that there is an exchange of approximately equal value. These are exchange transactions and are addressed in other CPSASs.

9. In other transactions, an entity will receive resources and provide no or nominal consideration directly in return. These are clearly non-exchange transactions and are addressed in this Standard. For example, taxpayers pay taxes because the tax law mandates the payment of those taxes. While the taxing government will provide a variety of public services to taxpayers, it does not do so in consideration for the payment of taxes.

10. There is a further group of non-exchange transactions where the entity may provide some consideration directly in return for the resources received, but that consideration does not approximate the fair value of the resources received. In these cases, the entity determines whether there is a combination of exchange and non-exchange transactions, each component of which is recognized separately. For example, an entity receives CU6 million funding from a multi-lateral development agency. The agreement stipulates that the entity must repay CU5 million of the funding received over a period of 10 years, at 5% interest when the market rate for a similar loan is 11%. The entity has effectively received a CU1 million grant (CU6 million received less CU5 million to be repaid) and entered into CU5 million concessionary loan which attracts interest at 6% below the market interest rate for a similar loan. The CU1 million grant received, as well as the off-market portion of the interest payments in terms of the agreement, are non-exchange transactions. The contractual capital and interest payments over the period of the loan are exchange transactions.

11. There are also additional transactions where it is not immediately clear whether they are exchange or non-exchange transactions. In these cases, an examination of the substance of the transaction will determine if they are exchange or non-exchange transactions. For example, the sale of goods is normally classified as an exchange transaction. If, however, the transaction is conducted at a subsidized price, that is, a price that is not approximately equal to the fair value of the goods sold, that transaction falls within the definition of a non-exchange transaction. In determining whether the substance of a transaction is that of a non-exchange or an exchange transaction, professional judgment is exercised. In addition, entities may receive trade discounts, quantity discounts, or other reductions in the quoted price of assets for a variety of reasons. These reductions in price do not necessarily mean that the transaction is a non-exchange transaction.

**Revenue**

12. Revenue comprises gross inflows of economic benefits or service potential received and receivable by the reporting entity, which represents an increase in net assets/equity, other than increases relating to contributions from owners. Amounts collected as an agent of the government or another government organization or other third parties will not give rise to an increase in net assets or revenue of the agent. This is because the agent entity cannot control the use of, or otherwise benefit from, the collected assets in the pursuit of its objectives.

13. Where an entity incurs some cost in relation to revenue arising from a non- exchange transaction, the revenue is the gross inflow of future economic benefits or service potential, and any outflow of resources is recognized as a cost of the transaction. For example, if a reporting entity is required to pay delivery and installation costs in relation to the transfer of an item of plant to it from another entity, those costs are

recognized separately from revenue arising from the transfer of the item of plant. Delivery and installation costs are included in the amount recognized as an asset, in accordance with CPSAS 17, *Property, Plant, and Equipment*.

**Stipulations**

14. Assets may be transferred with the expectation and/or understanding that they will be used in a particular way and, therefore, that the recipient entity will act or perform in a particular way. Where laws, regulations, or binding arrangements with external parties impose terms on the use of transferred assets by the recipient, these terms are stipulations, as defined in this Standard. A key feature of stipulations, as defined in this Standard, is that an entity cannot impose a stipulation on itself, whether directly or through an entity that it controls.

15. Stipulations relating to a transferred asset may be either conditions or restrictions. While conditions and restrictions may require an entity to use or consume the future economic benefits or service potential embodied in an asset for a particular purpose (performance obligation) on initial recognition, only conditions require that future economic benefits or service potential be returned to the transferor in the event that the stipulation is breached (return obligation).

16. Stipulations are enforceable through legal or administrative processes. If a term in laws or regulations or other binding arrangements is unenforceable, it is not a stipulation as defined by this Standard. Constructive obligations do not arise from stipulations. CPSAS 19, *Provisions, Contingent Liabilities and Contingent Assets*, establishes requirements for the recognition and measurement of constructive obligations.

**Conditions on Transferred Assets**

17. Conditions on transferred assets (hereafter referred to as conditions) require that the entity either consume the future economic benefits or service potential of the asset as specified, or return future economic benefits or service potential to the transferor in the event that the conditions are breached. Therefore, the recipient incurs a present obligation to transfer future economic benefits or service potential to third parties when it initially gains control of an asset subject to a condition. This is because the recipient is unable to avoid the outflow of resources, as it is required to consume the future economic benefits or service potential embodied in the transferred asset in the delivery of particular goods or services to third parties, or else to return to the transferor future economic benefits or service potential. Therefore, when a recipient initially recognizes an asset that is subject to a condition, the recipient also incurs a liability.

18. As an administrative convenience, a transferred asset, or other future economic benefits or service potential, may be effectively returned by deducting the amount to be returned from other assets due to be transferred for other purposes. The reporting entity will still recognize the gross amounts in its financial statements, that is, the

entity will recognize a reduction in assets and liabilities for the return of the asset under the terms of the breached condition, and will reflect the recognition of assets, liabilities, and/or revenue for the new transfer.

### Restrictions on Transferred Assets

19. Restrictions on transferred assets (hereafter referred to as restrictions) do not include a requirement that the transferred asset, or other future economic benefits or service potential, is to be returned to the transferor if the asset is not deployed as specified. Therefore, gaining control of an asset subject to a restriction does not impose on the recipient a present obligation to transfer future economic benefits or service potential to third parties when control of the asset is initially gained. Where a recipient is in breach of a restriction, the transferor, or another party, may have the option of seeking a penalty against the recipient, by, for example, taking the matter to a court or other tribunal, or through an administrative process such as a directive from a government minister or other authority, or otherwise. Such actions may result in the entity being directed to fulfill the restriction or face a civil or criminal penalty for defying the court, other tribunal, or authority. Such a penalty is not incurred as a result of acquiring the asset, but as a result of breaching the restriction.

### Substance over Form

20. In determining whether a stipulation is a condition or a restriction, it is necessary to consider the substance of the terms of the stipulation and not merely its form. The mere specification that, for example, a transferred asset is required to be consumed in providing goods and services to third parties or be returned to the transferor is, in itself, not sufficient to give rise to a liability when the entity gains control of the asset.

21. In determining whether a stipulation is a condition or restriction, the entity considers whether a requirement to return the asset or other future economic benefits or service potential is enforceable, and would be enforced by the transferor. If the transferor could not enforce a requirement to return the asset or other future economic benefits or service potential, the stipulation fails to meet the definition of a condition, and will be considered a restriction. If past experience with the transferor indicates that the transferor never enforces the requirement to return the transferred asset or other future economic benefits or service potential when breaches have occurred, then the recipient entity may conclude that the stipulation has the form but not the substance of a condition, and is, therefore, a restriction. If the entity has no experience with the transferor, or has not previously breached stipulations that would prompt the transferor to decide whether to enforce a return of the asset or other future economic benefits or service potential, and it has no evidence to the contrary, it would assume that the transferor would enforce the stipulation and, therefore, the stipulation meets the definition of a condition.

22. The definition of a condition imposes on the recipient entity a performance obligation – that is, the recipient is required to consume the future economic benefits or service potential embedded in the transferred asset as specified, or return the asset or other future economic benefits or service potential to the transferor. To satisfy the definition of a condition, the performance obligation will be one of substance not merely form, and is required as a consequence of the condition itself. A term in a transfer agreement that requires the entity to perform an action that it has no alternative but to perform may lead the entity to conclude that the term is in substance neither a condition nor a restriction. This is because, in these cases, the terms of the transfer itself do not impose on the recipient entity a performance obligation.

23. To satisfy the criteria for recognition as a liability, it is necessary that an outflow of resources will be probable, and performance against the condition is required and is able to be assessed. Therefore, a condition will need to specify such matters as the nature or quantity of the goods and services to be provided or the nature of assets to be acquired as appropriate and, if relevant, the periods within which performance is to occur. In addition, performance will need to be monitored by, or on behalf of, the transferor on an ongoing basis. This is particularly so where a stipulation provides for a proportionate return of the equivalent value of the asset if the entity partially performs the requirements of the condition, and the return obligation has been enforced if significant failures to perform have occurred in the past.

24. In some cases, an asset may be transferred subject to the stipulation that it be returned to the transferor if a specified future event does not occur. This may occur where, for example, a national government provides funds to a provincial government entity subject to the stipulation that the entity raise a matching contribution. In these cases, a return obligation does not arise until such time as it is expected that the stipulation will be breached, and a liability is not recognized until the recognition criteria have been satisfied.

25. However, recipients will need to consider whether these transfers are in the nature of an advance receipt. In this Standard, advance receipt refers to resources received prior to a taxable event or a transfer arrangement becoming binding. Advance receipts give rise to an asset and a present obligation because the transfer arrangement has not yet become binding. Where such transfers are in the nature of an exchange transaction, they will be dealt with in accordance with CPSAS 9.

**Taxes**

26. Taxes are the major source of revenue for many governments and other public sector entities. Taxes are defined in paragraph 7 as economic benefits compulsorily paid or payable to public sector entities, in accordance with laws or regulation, established to provide revenue to the government, excluding fines or other penalties imposed for breaches of laws or regulation. Noncompulsory transfers to the government or public

sector entities such as donations and the payment of fees are not taxes, although they may be the result of non-exchange transactions. A government levies taxation on individuals and other entities, known as taxpayers, within its jurisdiction by use of its sovereign powers.

27. Tax laws and regulations can vary significantly from jurisdiction to jurisdiction, but they have a number of common characteristics. Tax laws and regulations (a) establish a government's right to collect the tax, (b) identify the basis on which the tax is calculated, and (c) establish procedures to administer the tax, that is, procedures to calculate the tax receivable and ensure payment is received. Tax laws and regulations often require taxpayers to file periodic returns to the government agency that administers a particular tax. The taxpayer generally provides details and evidence of the level of activity subject to tax, and the amount of tax receivable by the government is calculated. Arrangements for receipt of taxes vary widely but are normally designed to ensure that the government receives payments on a regular basis without resorting to legal action. Tax laws are usually rigorously enforced and often impose severe penalties on individuals or other entities breaching the law.

28. Advance receipts, being amounts received in advance of the taxable event, may also arise in respect of taxes.

## Analysis of the Initial Inflow of Resources from Non-Exchange Transactions

29. An entity will recognize an asset arising from a non-exchange transaction when it gains control of resources that meet the definition of an asset and satisfy the recognition criteria. In certain circumstances, such as when a creditor forgives a liability, a decrease in the carrying amount of a previously recognized liability may arise. In these cases, instead of recognizing an asset, the entity decreases the carrying amount of the liability. In some cases, gaining control of the asset may also carry with it obligations that the entity will recognize as a liability. Contributions from owners do not give rise to revenue, so each type of transaction is analyzed, and any contributions from owners are accounted for separately. Consistent with the approach set out in this Standard, entities will analyze non-exchange transactions to determine which elements of general purpose financial statements will be recognized as a result of the transactions. The flow chart on the following page illustrates the analytic process an entity undertakes when there is an inflow of resources to determine whether revenue arises. This Standard follows the structure of the flowchart. Requirements for the treatment of transactions are set out in paragraphs 30–115.

**Illustration of the Analysis of Initial Inflows of Resources** [1]




1. The flowchart is illustrative only, it does not take the place of this Standard. It is provided as an aid to interpreting this Standard.

2. In certain circumstances, such as when a creditor forgives a liability, a decrease in the carrying amount of a previously recognized liability may arise. In these cases, instead of recognizing an asset, the entity decreases the carrying amount of the liability.

3. In determining whether the entity has satisfied all of the present obligations, the application of the definition of conditions on a transferred asset, and the criteria for recognizing a liability, are considered.

## Recognition of Assets

30. Assets are defined in CPSAS 1 as resources controlled by an entity as a result of past events, and from which future economic benefits or service potential are expected to flow to the entity.

31. **An inflow of resources from a non-exchange transaction, other than services in-kind, that meets the definition of an asset shall be recognized as an asset when, and only when:**

    (a) **It is probable that the future economic benefits or service potential associated with the asset will flow to the entity; and**

    (b) **The fair value of the asset can be measured reliably.**

### Control of an Asset

